**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

***Royal University of Law and Economics***


# សារណាបញ្ចប់ការសិក្សា

# ប្រាតិភោគនៅក្រុមហ៊ុនវីប្រេស្តាប្រថឹធី

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ៣១ ខែ មិថុនា ឆ្នាំ ២០១៤


រៀបរៀងឡើងដោយ

និស្សិតឈ្មោះ **មូល ភិរុណា**

**ស៊ាន សុខលាង**

សាស្ត្រាចារ្យណែនាំ

លោក **ជិន ចណ្ណារ៉ា**



ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០

សរសេរសារណា ២០១៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ សូមថ្លែងអំណរគុណចំពោះលោកអ្នកមានគុណ ដែលបានចិញ្ចឹមបីបាច់ថែរក្សា ថ្នាក់ថ្នម និងផ្គត់ផ្គងដល់រូបយើងខ្ញុំតាំងពីតូចរហូតពេញវ័យ និងទទួលបានចំណេះដឹងដ៏ខ្ពង់ខ្ពស់ ព្រមទាំងមានចរិយាថ្លៃថ្នូរសមជាពលរដ្ឋខ្មែរ។ យើងខ្ញុំ សូមដឹងគុណ និងតបស្នងគុណចំពោះលោកអ្នកមានគុណវិញ ដោយបំពេញនៅក្នុងតួនាទីជាកូនកតញ្ញូចំពោះលោកអ្នកមានគុណទាំងពីរ។

យើងខ្ញុំ ក៏សូមអរគុណចំពោះ ឯកឧត្តមវិទ្យាធិការ សាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ និងបុគ្គលិកសិក្សាទាំងអស់ដែលកំពុងបម្រើការក្នុងសាកលវិទ្យា-ល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានជួសម្រួលដល់រូបយើងខ្ញុំ ដើម្បីសិក្សាស្រាវជ្រាវក៏ដូចជាផ្តល់នូវទំនាក់ទំនងល្អជាមួយរូបយើងខ្ញុំយ៉ាងកក់ក្តៅ និងស្និទ្ធស្នាល។

យើងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះលោកសាស្ត្រាចារ្យ ជិន វណ្ណារា ដែលបានលះបង់កម្លាំងកាយ កម្លាំងចិត្ត និងចំណាយពេលវេលាយ៉ាងច្រើនដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀនរូបយើងខ្ញុំ ក្នុងម៉ោងសិក្សាព្រមទាំងណែនាំការសរសេរសារណាដល់រូបយើងខ្ញុំ។

យើងខ្ញុំសូមឧទ្ទិសស្នាដៃនេះ ចំពោះវីរជន វីរនារី មានឈាមជ័រជាខ្មែរទាំងអស់ ដែលបានធ្វើពលីកម្មក្នុងបុព្វហេតុជាតិមាតុភូមិជាទីស្រឡាញ់នៃយើងនោះឲ្យទទួលនូវ សន្តិភាព វឌ្ឍនភាព យុត្តិធម៌ សច្ចៈភាព និងមានការរីកចម្រើនរុងរឿងរហូតដល់បច្ចុប្បន្ន។

ជាចុងក្រោយនេះ យើងខ្ញុំសូមគោរពជូនពរ លោកអ្នកមានគុណខាងលើ ទទួលបាននូវជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

ការសិក្សាស្រាវជ្រាវ ប្រធានបទស្តី ប្រាតិភោគនៅក្រុមហ៊ុនវីប្រ៉េក្កាប្រចឹធី ត្រូវបានចងក្រងឡើងអស់ពីកម្លាំងកាយចិត្តដើម្បីឲ្យវាក្លាយជាឯកសារសម្រាប់បំពេញតម្រូវការរបស់អ្នកសិក្សាផ្នែកច្បាប់ និងអ្នកដែលចង់យល់ដឹងពីវិស័យផ្នែកច្បាប់ឲ្យកាន់តែច្បាស់ពីការអនុវត្តជាក់ស្តែងនូវប្រាតិ-ភោគនៅក្នុងក្រុមហ៊ុនឯកជនមួយនេះ។ ការសរសេរប្រធាននេះ វាជារង្វាស់មួយសម្រាប់វាស់សមត្ថភាពយល់ដឹង និងវាយតម្លៃចំណេះដឹងរបស់យើងខ្ញុំក្នុងវិស័យច្បាប់ដែលបានសិក្សារយៈពេលបួនឆ្នាំកន្លងមក។

ចំពោះការសរសេរប្រធានបទនេះ គឺយើងខ្ញុំបានចុះទៅកាន់ក្រុមហ៊ុនវីប្រ៉េក្កាប្រចឹធីផ្ទាល់ ហើយស្វែងយល់ ព្រមមានការសិក្សាទៅលើផ្នែកច្បាប់ ដែលមានឯកសារជាមូលដ្ឋានមួយចំនួនដូចជា ក្រមរដ្ឋប្បវេណី សន្ធានុក្រមរដ្ឋប្បវេណី សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ប្រកាសមួយចំនួន និងសារណាបញ្ចប់ឆ្នាំសិក្សារបស់និស្សិតរៀមច្បងនានាផងដែរ។ ស្នាដៃនេះគ្រាន់តែជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយៗ និងអ្នកសិក្សាទាំងឡាយ ក្នុងការស្វែងយល់នូវការចេះដឹងចំពោះករណីដែលពិបាកនឹងស្វែងរកឯកសារបំពេញបន្ថែម។ ដូចនេះ ក្នុងនាមយើងជាអ្នកចងក្រងសូមអភ័យទោសចំពោះកំហុសឆ្គង ទាំងឡាយ ដោយអចេតនាទាំងអត្ថន័យ និងអក្ខរាវិរុទ្ធខ្លះៗដែលមាននៅក្នុងសៀវភៅនេះ ហើយយើងខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោកសាស្ត្រាចារ្យ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ ក្រោយពីស្វែងយល់ពីអត្ថន័យនេះរួចហើយប្រាកដជាជួយស្វែងយល់ទិតៀន ដើម្បីស្ថាបនា និងកែសម្រួលជាក់ជាមិនខានក្នុងការផ្តល់នូវ ផលប្រយោជន៍ចំណេះដឹងដល់អ្នកសិក្សាជំនាន់ក្រោយៗទៀត។

យើងខ្ញុំ សូមជូនពរដល់ប្រិយមិត្ត និស្សិត អ្នកអាន អ្នកស្រាវជ្រាវ ដែលបានចំណាយពេលវេលាមកយកចិត្តទុកដាក់ និងផ្តោតអារម្មណ៍មកលើប្រធានបទនេះ និងសូមជួបប្រទះនូវសេចក្តីសុខ សុភមង្គលនៅក្នុងជីវិត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................................ ១

## ជំពូកទី ១

## ការបញ្ចាំ

**១.១ សញ្ញាណទូទៅ នៃការបញ្ចាំ** ........................................................ ៣

១.១.១ សញ្ញាណសំខាន់ៗទាក់ទងនឹងការបញ្ចាំ ........................................ ៣

១.១.១.១ អត្ថន័យនៃសិទ្ធិលើការបញ្ចាំ ........................................ ៣

១.១.១.២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា ........................................ ៤

១.១.១.៣ លក្ខខណ្ឌក្នុងប្រកបអាជីវកម្មទទួលបញ្ចាំវត្ថុ ........................................ ៥

១.១.២ ការបង្កើតកិច្ចសន្យាបញ្ចាំ ........................................ ៧

១.១.២.១ ល័ក្ខខ័ណ្ឌសុពលភាព ........................................ ៧

១.១.២.២ ល័ក្ខខ័ណ្ឌជំទាស់នឹងតតិយជន ........................................ ១០

១.១.៣ កម្មវត្ថុនៃកិច្ចសន្យាបញ្ចាំ ........................................ ១០

១.១.៣.១ ការបញ្ចាំចលនវត្ថុ ........................................ ១១

១.១.៣.២ ការបញ្ចាំអចលនវត្ថុ ........................................ ១២

១.១.៣.៣ ការបញ្ចាំសិទ្ធិ ........................................ ១២

**១.២ ប្រតិបត្តការបញ្ចាំនៅក្រុមហ៊ុនវីហ្វោប្រថីធី** ........................................ ១៤

១.២.១ ការព្រមព្រៀងលើសេវា ........................................ ១៤

១.២.១.១ ប្រភេទទ្រព្យ................................................................................................... ១៤

១.២.១.២ ចំនួនប្រាក់កម្ចី និងរយៈពេលនៃការបញ្ចាំ............................................................ ១៥

១.២.១.៣ សោហ៊ុយលើសេវា .............................................................................................. ១៥

១.២.១.៤ តម្លៃការប្រាក់ ..................................................................................................... ១៥

១.២.១.៥ ឯកសារដែលត្រូវភ្ជាប់ ......................................................................................... ១៦

១.២.១.៦ សេវារំលស់លើបំណុលមុនរបស់កូនបំណុល .................................................. ១៦

១.២.២ ការបំពេញបែបបទក្នុងការចុះកិច្ចសន្យា និងការដោះបំណុល.................................... ១៦

១.២.២.១ ករណីអតិថិជនមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង ....... ១៦

ក. កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ........................................................... ១៧

ខ. កិច្ចសន្យាបញ្ចាំអចលនវត្ថុ .................................................................................... ១៧

គ កិច្ចសន្យាបញ្ចាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ .............................................. ១៧

ឃ. ការផ្ទេរកម្មសិទ្ធិនៅសមត្ថកិច្ចដែនដី................................................................. ១៧

ង. ការកាន់កាប់សំណុំឯកសារ..................................................................................... ១៨

ច. ការដោះបំណុល ..................................................................................................... ១៨

ច.១ លិខិតបញ្ជាក់ការរួចបំណុល ................................................................................ ១៨

ច.២ ការដោះបំណុលនៅសមត្ថកិច្ចដែនដី.................................................................... ១៩

១.២.២.២ ករណីអតិថិជនមានប័ណ្ណសម្គាល់កម្មសិទ្ធិ(ប្លង់រឹង).......................................... ១៩

ក. កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ............................................................ ១៩

ខ. កិច្ចសន្យាបញ្ចាំអចលនវត្ថុ .................................................................................... ១៩

គ. កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ.........................................................................២០

ឃ. ការដោះបំណុល ....... ២០

ង. ការដោះបំណុល ....... ២០

# ជំពូក ២

# ប្រាតិភោគដោយអនុប្បទាន

**២.១ សញ្ញាណទូទៅនៃប្រាតិភោគដោយអនុប្បទាន** ....... ២១

២.១.១ កំណត់បង្ហាញនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន ....... ២២

២.១.១.១ សញ្ញាណប្រាតិភោគដោយអនុប្បទាននៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ....... ២២

២.១.២ ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន ....... ២៣

២.១.២.១ ល័ក្ខខ័ណ្ឌគ្រឹះ ....... ២៤

ក. ការព្រមព្រៀង ....... ២៤

ខ. សមត្ថភាព ....... ២៥

គ. កម្មវត្ថុ ....... ២៦

២.១.២.២ លក្ខខណ្ឌទម្រង់ ....... ២៩

២.១.២.៣ លក្ខខណ្ឌតតាំង ....... ៣០

**២.២ ប្រាតិភោគដោយអនុប្បទាននៅក្រុមហ៊ុនវីប្រេក្កាប្រចឹធី** ....... ៣២

២.២.១ ការព្រមព្រៀងលើសេវា ....... ៣២

២.២.១.១ ប្រភេទទ្រព្យ ....... ៣២

២.២.១.២ រយៈពេលនៃប្រាតិភោគដោយអនុប្បទាន ....... ៣២

២.២.១.៣ សោហ៊ុយលើសេវា ....... ៣៣

២.២.១.៤ តម្លៃការប្រាក់ ....... ៣៣

២.២.១.៥ ឯកសារដែលត្រូវភ្ជាប់ ........................................................................ ៣៣

២.២.២ ការបំពេញបែបបទចុះកិច្ចសន្យា ........................................................................ ៣៤

២.២.២.១ កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ........................................................ ៣៤

២.២.២.២ លិខិតធានាអះអាងចំពោះចលនវត្ថុសម្រាប់ជាប្រាតិភោគដោយអនុប្បទាន........... ៣៤

២.២.២.៣ កិច្ចព្រមព្រៀងបន្ថែមលើកិច្ចសន្យាទទួលប្រាតិភោគដោយអនុប្បទាន ........... ៣៤

២.២.២.៤ កិច្ចសន្យាទទួលប្រាតិភោគដោយអនុប្បទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ......... ៣៥

២.២.៣ ការដោះបំណុល ........................................................................ ៣៥

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........................................................................ ៣៦

**ឯកសារពិគ្រោះ**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ដោយសារតែមនុស្សម្នាក់ៗពុំអាចសម្រេចកិច្ចការតែម្នាក់ឯងបានទេតែងតែត្រូវការជំនួយពីអ្នកដទៃ ដើម្បីសម្រេចកិច្ចការរបស់ខ្លួន នោះក្នុងការរស់នៅប្រចាំថ្ងៃយើងតែងតែសង្កេតឃើញថាមនុស្សក្នុងសង្គមចៀសមិនផុតពីការខ្ចីប្រាក់កាស ស្រូវអង្ករ គ្រឿងអលង្ការ របស់របរប្រើប្រាស់ និងរបស់របរផ្សេងៗទៀត ព្រោះតែពួកគេពុំអាចមានវត្ថុគ្រប់ទាំងអស់ឡើយ។បើយើងនិយាយថាពាក្យប្រាតិភោគ សម្រាប់ប្រជាពលរដ្ឋធម្មតាប្រហែលជាពិបាកយល់ពីខ្លឹមសារពាក្យនេះច្បាស់លាស់ណាស់។ ជាធម្មតានៅពេលដែលប្រជា-ពលរដ្ឋខ្ចីប្រាក់ពីធនាគារ ម្ចាស់ប្រាក់(ធនាគារ) តែងតែតម្រូវឲ្យពួកគាត់យកទ្រព្យទៅដាក់បញ្ចាំសម្រាប់កម្ចីនោះ ឬបើការខ្ចីប្រាក់បើមានម្ចាស់បំណុល គ្រាន់តែជាបុគ្គលរកធម្មតាតាមទីផ្សារ ក្នុងស្រុកភូមិទេនោះគេនិយមប្រើពាក្យថាយកទ្រព្យទៅដាក់កុងស៊ី។ ពាក្យថា បញ្ចាំ ឬកុងស៊ីបញ្ចាំ ជាពាក្យដែលប្រជាពលរដ្ឋធម្មតានិយមប្រើ ហើយក្នុងន័យថាយកទ្រព្យទៅប្រគល់ឲ្យម្ចាស់បំណុលទុកធានាប្រាក់កម្ចីដែលខ្លួនខ្ចីពីម្ចាស់បំណុលនោះ ហើយបើថ្ងៃក្រោយគ្មានប្រាក់សងទេ ម្ចាស់បំណុលគេនឹងរឹបអូសយកទ្រព្យនោះហើយ។ ជាទំលាប់មួយទៀតនៅពេលដែលគេយកវត្ថុអ្វីមួយទៅធ្វើការជួសជុល ដូចជានាឡិកាដៃ វិទ្យុជាដើម ហើយជាទូទៅបើម្ចាស់ទ្រព្យមិនទាន់មានប្រាក់ថ្លៃជួសជុលសម្រាប់ប្រគល់ឲ្យអ្នកជួសជុល គឺទ្រព្យនោះស្ថិតក្នុងដៃរបស់អ្នកជួសជុលរហូត ។ ទំលាប់នេះមានន័យថាម្ចាស់ទ្រព្យបានយល់ច្បាស់ថា អ្នកជួសជុលមានសិទ្ធិឃាត់ទុកនូវវត្ថុជួសជុល បើប្រាក់ថ្លៃជួសជុលមិនទាន់គ្រប់ឲ្យទេ។ រីឯចំពោះអ្នកខ្ចី (កូនបំណុល) វិញ តែងតែសងបំណុល ទៅឲ្យអ្នកដែលឲ្យខ្ចី (ម្ចាស់បំណុល) វិញនូវទំហំវត្ថុដែលខ្ចី និងមានប្រាក់ទៀតផង។ ប៉ុន្តែក៏មាន អ្នកខ្ចីខ្លះមានគំនិតទុច្ចរិតមិនព្រមសងទៅឲ្យម្ចាស់បំណុលវិញដែលចាហេតុធ្វើឲ្យមានរឿងប្តឹងផ្តល់នឹងគ្នា។ ករណីដែលកូនបំណុលខ្ចីប្រាក់ពុំសងខាងលើនេះ ជាហេតុធ្វើឲ្យម្ចាស់បំណុលទទួលនូវការបាត់បង់ធានាថានឹងសងម្ចាស់បំណុលវិញ។ ការធានានោះមានពីរប្រភេទគឺការធានាដោយបុគ្គល និងការធានាដោយវត្ថុ ហើយការធានាដោយបុគ្គល គឺមានបុគ្គលណាម្នាក់មក ធានាអះអាងចំពោះម្ចាស់បំណុលថាសងជំនួសកូនបំណុល បើសិនជាកូនបំណុលមិនបានបំពេញកាតព្វកិច្ចនោះទេ ដែលច្បាប់បានឲ្យឈ្មោះថា ប្រាតិភោគបាតិបុគ្គល ឬប្រាតិភោគដោយបុគ្គល។ ចំណែកឯការធានាដោយវត្ថុ ច្បាប់បានឲ្យឈ្មោះថា ប្រាតិភោគភណ្ឌិក ឬប្រាតិភោគប្រត្យ័ក្ស គឺកូនបំណុលយកវត្ថុ ដែល កម្មសិទ្ធិរបស់ខ្លួនមកធានាចំពោះម្ចាស់បំណុលរបស់ខ្លួនដើម្បីខ្ចីប្រាក់កាស ឬវត្ថុអ្វីមួយនោះហើយកាលណាកូនបំណុលមិនបានបំពេញកាតព្វកិច្ច នៅពេល

មកដល់ទេនោះម្ចាស់បំណុលមានសិទ្ធិប្តឹងទៅតុលាការដើម្បីរឹបអូសវត្ថុ ដែលជាកម្មវត្ថុនៃប្រាតិភោគនោះមកលក់ឡាយឡុង ដើម្បីទូទាត់សងបំណុលខ្លួនវិញ។

ក្រុមហ៊ុនវីប្រេ្កាប្រចឹធី ជាក្រុមហ៊ុនមួយដែលប្រតិបត្តិការតែប្រាតិភោគប្រត្យក្សប៉ុណ្ណោះ ហើយមានស្លាកឃីហោថា មានទទួលបញ្ចាំ និងប្រាតិភោគដោយអនុប្បទានផ្ទះ ដី រថយន្ត និងម៉ូតូ នេះសរឲ្យឃើញថាក្រុមហ៊ុននេះបម្រើសេវាផ្តល់ប្រាក់កម្ចី និងទទួលតែវត្ថុធានាដែលជាទ្រព្យរបស់កូនបំណុលតែប៉ុណ្ណោះ ហើយបុគ្គលពុំអាចធានាលើបំណុលបានឡើយ។ បច្ចុប្បន្នក្រុមហ៊ុននេះទទួលបានអតិថិជនមួយចំនួនផងដែរ ។ ជាក់ស្តែងតាមការរយៈអង្កេត និងស្វែងយល់របស់យើងខ្ញុំនៅក្នុងរយៈពេលបំពេញការងារផ្ទាល់នៅក្រុមហ៊ុននេះ ធ្វើឲ្យយើងខ្ញុំទទួលបានចំណេះដឹងមួយចំនួនព្រមទាំងបានយល់ដឹងពីលក្ខន្តិកៈនៅក្នុងប្រតិបត្តិការប្រាតិភោគនៃក្រុមហ៊ុននេះផងដែរ ។

ដើម្បីស្វែងយល់អំពីប្រតិបត្តិការប្រាតិភោគរបស់ក្រុមហ៊ុនវីប្រេ្កាប្រចឹធីនេះ យើងនឹងធ្វើការបកស្រាយទៅលើសេវាប្រាតិភោគទាំងពីររបស់ក្រុមហ៊ុននេះមានដូចជា ប្រតិបត្តិការបញ្ចាំ(ជំពូកទី-១) និងប្រតិបត្តិការប្រាតិភោគដោយអនុប្បទាន(ជំពូកទី២) ថាតើប្រតិបត្តិការទាំងពីររបស់ក្រុមហ៊ុននេះមានការអនុវត្តទៅយ៉ាងដូចម្តេចខ្លះ? ៖

# ជំពូកទី ១

# ការបញ្ចាំ

មុននឹងឈានដល់ការបកស្រាយអំពីប្រតិបត្តិបញ្ចាំនៅក្នុងក្រុមហ៊ុនវីប្រេ្កាប្រចឺធី (១.២) យើងគប្បីត្រូវដឹងអំពីសញ្ញាណទូទៅនៃការបញ្ចាំជាមុនសិន (១.១ )។

## ១.១ សញ្ញាណទូទៅ នៃការបញ្ចាំ

ប្រាកដណាស់ គោលបំណងនៅក្នុង ជំពូកទី១ នៃសារណានេះផ្ដោតទៅលើសញ្ញាណសំខាន់ៗទាក់ទងនឹងការបញ្ចាំ (១.១.១) និងការបង្កើតកិច្ចសន្យាបញ្ចាំ(១.១.២) និងប្រភេទនៃកិច្ច-សន្យាបញ្ចាំ (១.១.៣) ។

### ១.១.១ សញ្ញាណសំខាន់ៗទាក់ទងនឹងការបញ្ចាំ

យើងបកស្រាយរួចហើយថាមុននឹងសញ្ញាណមួយ ត្រូវបានគេយកទៅប្រើប្រាស់លុះត្រាតែសញ្ញាណនោះ ត្រូវបានគេស្គាល់ជាមុនសិន។ ដូច្នេះនៅក្នុងកថាខណ្ឌនេះហើយនឹងធ្វើការបកស្រាយអំពីសញ្ញាណនៃការបញ្ចាំ ដូចជា និយមន័យនៃការបញ្ចាំ(១.១.១.១) ទំហំនៃសិទ្ធិលើបំណុលដែលត្រូវធានា (១.១.១.២) និងលក្ខខណ្ឌក្នុងការប្រកបអាជីវកម្មទទួលបញ្ចាំវត្ថុ(១.១.១.៣)។

#### ១.១.១.១ អត្ថន័យនៃសិទ្ធិលើការបញ្ចាំ

សិទ្ធិលើការបញ្ចាំ គឺសម្ដៅទៅលើម្ចាស់សិទ្ធិលើការបញ្ចាំ ឬហៅថាម្ចាស់បំណុល មានសិទ្ធិកាន់កាប់វត្ថុដែលទទួលបានពីកូនបំណុល ឬតតិយជនដើម្បីធានាសិទ្ធិលើបំណុលរបស់ខ្លួន និងទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីវត្ថុនោះវិញ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត[១]។ នោះមានន័យថា ការបញ្ចាំ គឺជាប្រភេទនៃកិច្ចសន្យាប្រាតិភោគមួយប្រភេទដែលកូនបំណុល ឬតតិយជន ត្រូវដាក់ទ្រព្យរបស់ខ្លួនទៅឲ្យម្ចាស់បំណុលកាន់កាប់ ដើម្បីធានានូវការសងបំណុលរបស់ខ្លួនទៅឲ្យម្ចាស់បំណុលកាន់កាប់ ដើម្បីធានានូវការសងបំណុលរបស់ខ្លួនទៅឲ្យម្ចាស់បំណុលវិញ។ ក្នុងករណីអ្នកបង្កើតសិទ្ធិលើការបញ្ចាំ មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការសង

[១] មាត្រា ៨១៦ នៃក្រមរដ្ឋប្បវេណី ២០០៧

បំណុលនោះទេ ម្ចាស់សិទ្ធិលើការបញ្ចាំ អាចទទួលការសងចំពោះសិទ្ធិលើបំណុលរបស់ខ្លួនពីតម្លៃថ្នូរនៃវត្ថុបញ្ចាំ ដោយមានអាទិភាពជាម្ចាស់បំណុលផ្សេងទៀត។

ក្រោយពីយល់អំពីអត្ថន័យអំពីសិទ្ធិលើការបញ្ចាំ យើងនឹងបន្តទៅសិក្សាសញ្ញាណមួយទៀតគឺទាក់ទងនឹងសិទ្ធិនឹងការទាមទារបំណុល និងប្រាក់ផ្សេងៗទៀតរបស់ម្ចាស់សិទ្ធិលើកាបញ្ចាំនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ ដូច្នេះ តើទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានាចំពោះម្ចាស់សិទ្ធិមានទំហំប៉ុណ្ណា? ហើយអ្វីខ្លះ?

### ១.១.១.២ ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា

ជាគោលការណ៍នៅពេលដែលភាគីម្ខាងនៃកិច្ចសន្យារំលោភបំពានមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនដែលមានចែងនៅក្នុងកិច្ចសន្យាជាក់លាក់ណាមួយ វាប្រាកដជាធ្វើឲ្យភាគីម្ខាងទៀតទទួលរងនូវការខាតបង់ជាក់ជាមិនខាន។ ដូច្នេះហើយ ទើបច្បាប់បញ្ញត្តិការពារដល់ភាគីរងគ្រោះដោយសារការរំលោភបំពាននេះ មានសិទ្ធិប្ដឹងទាមទារឲ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ ស្នើសុំសំណងនៃការខូចខាត និងស្នើសុំរំលាយកិច្ចសន្យាជាដើម ដែលបទបញ្ញត្តិទាំងនេះមានចែងនៅក្នុងគន្ថីទី ៤ ជំពូកទី ៤ ការសង្គ្រោះចំពោះការបំពានលើកិច្ចសន្យា។ យ៉ាងណាមិញ ទាក់ទងទៅនឹងការអនុវត្តសិទ្ធិលើការបញ្ចាំនៅពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ម្ចាស់សិទ្ធិលើការបញ្ចាំមានសិទ្ធិលើការបញ្ចាំមានសិទ្ធិដាក់ពាក្យសុំលក់ដោយបង្ខំទៅតុលាការ នូវវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាបញ្ចាំ ដើម្បីយកប្រាក់ដែលលក់បាន យកមកទូទាត់សងបំណុល និងសងសំណងនៃការខូចខាត ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។

ទំហំនៃសិទ្ធិលើបំណុលដែលត្រូវបានធានា គឺជាទំហំនៃសិទ្ធិដែលម្ចាស់សិទ្ធិល់ការបញ្ចាំមានសិទ្ធិប្ដឹងទាមទារសំណងនៃការខូចខាត ដែលកើតឡើងដោយសារការរំលោភបំពានរបស់អ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដូចជាប្រាក់ដើម ការប្រាក់ ប្រាក់ធានាសងក្នុងករណីមិនគោរពកិច្ចសន្យាសោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ សោហ៊ុយដើម្បីថែរក្សាវត្ថុបញ្ចាំ ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងដោយសារការមិនអនុវត្តកាតព្វកិច្ច ឬវិការៈកំបាំងនៃវត្ថុបញ្ចាំ[២]។ ក្នុងករណីដែលប្រាក់បានមកពីការលក់ដោយបង្ខំនូវវត្ថុបញ្ចាំ ក្រោយពីសងទៅម្ចាស់សិទ្ធិលើការបញ្ចាំ និងសំណងផ្សេងទៀតដែលបានទាមទារខាងលើរួចរាល់ ប្រសិនបើនៅសល់ត្រូវយកប្រាក់ទាំងនោះទៅទូទាត់

[២] មាត្រា ៨២០ នៃក្រមរដ្ឋប្បវេណី ២០០៧

សងទៅម្ចាស់បំណុលដែលមានអាទិភាពបន្តបន្ទាប់ទៀត។ ប៉ុន្តែប្រសិនបើមិនមានម្ចាស់បំណុលទៀតនោះទេ ប្រាក់ដែលនៅសល់នឹងត្រូវប្រគល់ទៅឲ្យកូនបំណុលនៃការអនុវត្តវិញទាំងអស់។

ចំពោះការដែលម្ចាស់សិទ្ធិលើការបញ្ចាំ មានបុព្វសិទ្ធិ និងបុរិមាក្នុងការទទួលបានសំណងមុនម្ចាស់បំណុលផ្សេងទៀត ម្ចាស់សិទ្ធិលើការបញ្ចាំត្រូវតែគោរពនូវលក្ខខណ្ឌតតាំងចំពោះតតិយជនដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីជាដាច់ខាត។ សោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ គឺជាសោហ៊ុយ ទាំងឡាយណាដែលចំណាយទៅលើផ្លូវសោហ៊ុយដើម្បីអនុវត្តសិទ្ធិលើការបញ្ចាំ គឺជាសោហ៊ុយទាំងឡាយណាដែលចំណាយទៅលើផ្លូវច្បាប់ទាក់ទងទៅនឹងការអនុវត្តសិទ្ធិលើការបញ្ចាំ ដូចជាពន្ធដាក់ពាក្យសុំ ចំណាយសម្រាប់សេវាមេធាវី និងចំណាយផ្សេងៗទៀតពាក់ព័ន្ធទៅនឹងការអនុវត្តដោយបង្ខំ រហូតដល់ម្ចាស់សិទ្ធិលើការបញ្ចាំទទួលបានប្រាក់សំណង។

ដោយមើលឃើញនូវគុណសម្បត្តិខាងលើ តាមរយៈសិទ្ធិប្ដឹងទាមទារយកវត្ថុបញ្ចាំលក់ដោយបង្ខំ ដើម្បីទូទាត់បំណុល និងសិទ្ធិកាន់កាប់វត្ថុបញ្ចាំ ទើបធ្វើឲ្យយន្តការនៃការធានាបំណុលក្រោមរូបភាពនៃការបញ្ចាំ មានការពេញនិយមប្រើប្រាស់ជាងការដាក់ធានាបំណុលផ្សេងៗទៀតនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន។ ដូច្នេះ យើងនឹងបន្តធ្វើការសិក្សាទៅលើលក្ខខណ្ឌក្នុងការប្រកបអាជីវកម្មទទួលបញ្ចាំវត្ថុជាបន្តទៅទៀត។

### ១.១.១.៣ លក្ខខណ្ឌក្នុងប្រកបអាជីវកម្មទទួលបញ្ចាំវត្ថុ

នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្នអាជីវកម្មទទួលបញ្ចាំវត្ថុ មានការពេញនិយមជាខ្លាំងពីសំណាក់ប្រជាពលរដ្ឋទូទៅ និងធ្វើការបិទផ្សាយពាណិជ្ជកម្មទទួលបញ្ចាំវត្ថុស្ទើរតែគ្រប់ទីកន្លែងក្នុងទីក្រុងភ្នំពេញ។ នៅមុនឆ្នាំ ២០១០ អាជីវកម្មទទួលបញ្ចាំវត្ថុ គឺជាអាជីវកម្មមួយដែលគ្មានច្បាប់អនុញ្ញាតឲ្យប្រកបអាជីវកម្មឡើយ ប៉ុន្តែនៅតែមានប្រជាពលរដ្ឋមួយចំនួនធំនៅតែបន្តប្រកបអាជីវកម្មទទួលបញ្ចាំដោយខុសច្បាប់ ហើយថែមទាំងទទួលបញ្ចាំទាំងពេលយប់ និងពេលថ្ងៃ។ ការធ្វើបែបនេះផ្ដល់ផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គម ដោយវាបង្កើននូវអំពើចោរកម្មលួចឆក់ប្លន់ ហើយយកទ្រព្យដែលបានមកពីសកម្មភាពខុសច្បាប់ទាំងនោះ ទៅដាក់បញ្ចាំនៅកន្លែងទទួលបញ្ចាំ ឬកុងស៊ីបញ្ចាំទោះបីជាបានតម្លៃថោកជាងទីផ្សារក៏ដោយ។

ដោយមើលឃើញនូវភាពអាណាធិបតេយ្យនៃអាជីវកម្មទទួលបញ្ចាំវត្ថុ ឬកុងស៊ីបញ្ចាំ និងការកើនឡើងនូវអំពើចោរកម្មនៅក្នុងប្រទេស ទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាតើវិធានការ

ដើម្បីរឹតបន្តឹងការទទួលបញ្ចាំវត្ថុ ដោយផ្តល់អាជ្ញាប័ណ្ណដល់អាជីវកម្មទទួលបញ្ចាំទាំងនោះ ក្នុងគោលបំណងគ្រប់គ្រង និងដាក់អាជីវកម្មនេះឲ្យស្ថិតនៅក្រោមច្បាប់។ ជាពិសេស គឺឈានទៅលុបបំបាត់អំពើចោរកម្មដែលជាក្តីបារម្ភដ៏ធំបំផុតសម្រាប់ប្រជាពលរដ្ឋទូទៅ ហើយវាក៏ជាវិធីសាស្ត្រមួយដែលជួយបង្កើនប្រាក់ចំណូលរបស់រដ្ឋតាមរយៈការបង់ថ្លៃពន្ធផងដែរ។

យោងតាមប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២៨ សហវ-ប្រក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០១០ ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញលក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទានបានឲ្យដឹងថា ដើម្បីលើកកម្ពស់ការយល់ដឹងនៃការងារអាជីវកម្ម និងសណ្តាប់ធ្នាប់សង្គម តម្រូវឲ្យអាជីវកម្មទាំងអស់នៅក្នុងឧស្សាហកម្មនេះដាក់ពាក្យសុំអាជ្ញាប័ណ្ណនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលបានការណែនាំ និងរបៀបធ្វើអាជីវកម្ម។ បន្ថែមលើសពីនេះទៅទៀត ការប្រកួតអាជីវកម្មទទួលបញ្ចាំវត្ថុ ប្រតិបត្តិការទាំងអស់ត្រូវតែមានទុកអប្បបរមា ៨០រៀល (ប្រមាណជា ២ម៉ឺន ដុល្លារ) ដែលក្នុងនោះទុន ១០ភាគរយ ឬយ៉ាងច្រើនបំផុត ៥០លានរៀល ត្រូវតម្កល់ទុកនៅក្នុងគណនីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅធនាគារជាតិនៃកម្ពុជា(NBC)។ ជាងនេះទៅទៀត ប្រកាសខាងលើនេះ តម្រូវឲ្យអាជីវកម្មដែលដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទាំងអស់ បង់ថ្លៃអាជ្ញាប័ណ្ណចំនួន ២លានរៀល ឬ៥០០ដុល្លារ សម្រាប់ប្រចាំឆ្នាំ និងត្រូវបង់ពន្ធទៅអគ្គនាយកដ្ឋានរតនាគារជាតិតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាជីវកម្មទទួលបញ្ចាំ និងទិញលក់ទ្រព្យបញ្ចាំទាំងអស់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងតម្រូវឲ្យអាជីវកម្មទាំងអស់ ត្រូវធ្វើកិច្ចសន្យាបញ្ចាំជាលាយលក្ខណ៍អក្សរឲ្យបានត្រឹមត្រូវតាមច្បាប់ និងមិនត្រូវធ្វើអាជីវកម្មដើម្បីបម្រើដល់សកម្មភាពសម្អាតប្រាក់ ឬសម្រ់ផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ។ ហេតុដូចនេះ ប្រសិនបើអាជីវកម្មទទួលបញ្ចាំណាមួយ ទទួលបញ្ចាំ ឬទិញផលចោរកម្ម នោះនឹងត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងជនល្មើសផងដែរ។

ទោះបីជាអាជីវកម្មទទួលបញ្ចាំត្រូវបានរឹតត្បិតដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយ៉ាងនេះក៏ដោយ ក៏នៅតែអាជីវកម្មមួយចំនួនធំនៅតែមិនបានទៅសុំអាជ្ញាប័ណ្ណ ហើយក៏មិនបានអានុវត្តតាមការណែនាំរបស់ក្រសួងឡើយ។

## ១.១.២ ការបង្កើតកិច្ចសន្យាបញ្ចាំ

ការបង្កើតកិច្ចសន្យាបញ្ចាំ វាមានលក្ខណៈដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាដទៃទៀតដែរ ដែលវាទាមទារឲ្យភាគីនៃកិច្ចសន្យាគោរពនូវលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌពិសេស ដែលយើងអាចហៅថា លក្ខខណ្ឌសុពលភាព (១.១.២.១) ។ ជាងនេះទៅទៀត ដើម្បីឲ្យម្ចាស់បំណុលអាចយកសិទ្ធិរបស់ខ្លួនទៅជំទាស់ទៅនឹងការអះអាងរបស់តតិយជនបាន ការបង្កើតកិច្ចសន្យាបញ្ចាំ ត្រូវគោរពទៅលក្ខខណ្ឌជំទាស់នឹងតតិយជន (១.១.២.២) ដែលបានកំណត់ដោយច្បាប់។

### ១.១.២.១ លក្ខខណ្ឌសុពលភាព

ជាគោលការណ៍នៃការបង្កើតកិច្ចសន្យា ត្រូវគោរពទៅតាមបទបញ្ញត្តិទូទៅ និងបទបញ្ញត្តិពិសេស ។ នៅក្នុងករណីដែលបទបញ្ញត្តិពិសេសមិនមានចែង ត្រូវយកបទបញ្ញត្តិទូទៅយកមកអនុវត្ត។

ការរៀបចំបង្កើតកិច្ចសន្យាបញ្ចាំ ត្រូវគោរពលក្ខខណ្ឌដូចគ្នាទៅនឹងការបង្កើតកិច្ចសន្យាផ្សេងទៀតដែរ គឺត្រូវមានការព្រមព្រៀងដោយពិតប្រាកដ និងដោយសេរីរវាងអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬហៅថា កូនបំណុល និងម្ចាស់សិទ្ធិលើការបញ្ចាំ ឬហៅថា ម្ចាស់បំណុល។ ផ្ទុយទៅវិញប្រសិនបើមានវិការៈ នៃការព្រមព្រៀងដែលបានស្តែងឡើង នៅពេលបង្កើតកិច្ចសន្យាបញ្ចាំនោះនាំឲ្យកិច្ចសន្យាបញ្ចាំមិនអាចយកអនុវត្តទៅបានឡើយ។ ជាមួយគ្នានេះដែរដើម្បីឲ្យកិច្ចសន្យាបញ្ចាំមួយមានសុពលភាព និងអាចយកទៅអនុវត្តបាន ភាគីនៃកិច្ចសន្យាត្រូវតែជាជនដែលមានសមត្ថភាពពេញលេញ ក្នុងការបង្កើតកិច្ចសន្យាឲ្យស្របទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះជនដែលមានសមត្ថភាពចុះកិច្ចសន្យាទៅបាន មានតែជនដែលជាសមត្ថជនប៉ុណ្ណោះ។ ចំពោះជនដែលជាសមត្ថជន នៅក្នុងសទ្ទានុក្រម នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ទំព័រទី២១ សម្តៅទៅដល់ជនទាំងឡាយណា ក្រៅពីអនីតិជន លើកលែងតែអនីតិជន ដែលទទួលបានអត្តាធីនភាព។

នៅក្នុងកិច្ចសន្យាបញ្ចាំ ភាគីត្រូវកំណត់ចំនួនទឹកប្រាក់ជំពាក់ ការប្រាក់[៣] និងវត្ថុដែលដាក់បញ្ចាំឲ្យបានច្បាស់លាស់ ដែលវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំ យើងនឹងធ្វើការបកស្រាយនៅក្នុងចំណុច ១.៣ បន្ទាប់នេះ។ នៅក្នុងនោះដែរ ច្បាប់ក៏បានអនុញ្ញាតឲ្យភាគីនៃកិច្ចសន្យា ធ្វើការសន្យា

[៣] ការកំណត់អត្រាការប្រាក់ អាចកំណត់ទៅតាមការព្រមព្រៀង ប៉ុន្តែមិនឲ្យលើសពីច្បាប់កម្រិតនោះឡើយ។ ក្នុងការកំណត់អាត្រាការប្រាក់នៅក្នុងកិច្ចសន្យាឯកជនទូទៅ អត្រាការប្រាក់ត្រូវកម្រិតទៅតាមប្រកាសរបស់ក្រសួងយុត្តិធម៌។

ពិសេសនៅក្នុងសកម្មភាពបង្កើតសិទ្ធិលើការបញ្ចាំ ដូចជាការកម្រិតអត្រាការប្រាក់ និងការអនុញ្ញាត ឬមិនអនុញ្ញាតឲ្យម្ចាស់បំណុលប្រើប្រាស់ និងអាស្រ័យផលទ្រព្យបញ្ចាំជាដើម។

លើសពីនេះទៅទៀត នៅក្នុងកិច្ចសន្យាបញ្ចាំ ត្រូវកំណត់ពេលវេលាត្រូវសងឲ្យបានច្បាស់លាស់។ នៅក្នុងការបង្កើតសិទ្ធិលើការបញ្ចាំចំពោះចលនវត្ថុ និងការបញ្ចាំសិទ្ធិលើបំណុល ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនបានកំណត់ថិរវេលាច្បាស់លាស់នោះទេ លើកលែងតែការបញ្ចាំអចលនវត្ថុប៉ុណ្ណោះ ដែលមានថេរវេលាកំណត់ត្រឹម៥ ឆ្នាំប៉ុណ្ណោះ។ ដូច្នេះក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុរួចទៅហើយ ហើយអំឡុងពេលមានអត្ថិភាពលើសពី ៥ឆ្នាំ ដោយកំណត់ទៅតាមច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ២០៩ កថាខណ្ឌទី២ អំឡុងពេលនៃការដាក់បញ្ចាំអចលនវត្ថុមិនអាចលើសពី ១០ឆ្នាំ បានឡើយ។ នៅក្នុងករណីនេះ ទោះបីជាការបង្កើតនេះមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ឬក្រោយកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ក៏ដោយក៏អំឡុងពេលដែលមានអត្ថិភាពនឹងត្រូវបន្ថយមកត្រឹម ៥ឆ្នាំវិញ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី។ ប្រសិនបើសិទ្ធិលើការបញ្ចាំបានដល់រយៈពេលកំណត់៥ឆ្នាំសិទ្ធិលើការបញ្ចាំអចលនវត្ថុអាចបន្តសារជាថ្មីទៀតបាន ប៉ុន្តែអំឡុងពេលនៃការបន្តនេះពុំអាចកំណត់ឲ្យលើសពី ៥ឆ្នាំឡើយ ដោយគិតចាប់ពីពេលបន្តនេះទៅ[៤] ។

ការបង្កើតកិច្ចសន្យាបញ្ចាំគឺផ្តោតទៅលើការប្រគលវត្ថុបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ និងបានហាមមិនឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ ឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំនោះកាន់កាប់ដោយផ្ទាល់លើវត្ថុបញ្ចាំនោះទេ[៥]។ នោះមានន័យថា សិទ្ធិលើការបញ្ចាំមិនត្រូវបានកើតឡើងអានុភាពនោះទេ ប្រសិនបើវត្ថុដែលជាកម្មវត្ថុនៃការបញ្ចាំនោះមិនត្រូវបានប្រគល់ទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់។ ចំពោះទម្រង់នៃកិច្ចសន្យាបញ្ចាំ ដែលថា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬមិនលាយលក្ខណ៍អក្សរ និងជាលិខិតយថាភូត ឬយ៉ាងណានោះ នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនតម្រូវឲ្យមានទម្រង់ពិសេសណាមួយនោះទេគឺគ្រាន់តែតម្រូវឲ្យមានការព្រមព្រៀងរបស់ភាគីតែប៉ុណ្ណោះ។ រីឯក្រឹត្យច្បាប់លេខ ៣៨ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាកិច្ចសន្យា ត្រង់មាត្រា ៦៥ ដែលបាននិរាករណ៍ហើយនោះ បានចែងអំពីការបង្កើតកិច្ចសន្យាបញ្ចាំចលនវត្ថុ កិច្ចសន្យាបញ្ចាំត្រូវធ្វើឡើងជាឱឡារិក និងភណ្ឌិក ហើយតម្រូវឲ្យធ្វើជាលាយលក្ខណ៍

[៤] មាត្រា ៨៣៨ នៃក្រមរដ្ឋប្បវេណី ២០០៧ និងមាត្រា ៥៧នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១

[៥] ទម្រង់កិច្ចសន្យាបង្កើតសិទ្ធិលើបញ្ចាំ

អក្សរ ហើយកិច្ចសន្យានេះ នឹងអាចយកជាការបានលុះត្រាតែទ្រព្យដាក់ធានាត្រូវបានប្រគល់ដល់ដៃម្ចាស់បំណុល។

ចំណែកលក្ខខណ្ឌទម្រង់ក្នុងការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុវិញ នៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ ត្រង់មាត្រា ២០៧ ដែលបាននិរាករណ៍ផងដែរនោះ បានចែងថា កិច្ចសន្យាបញ្ចាំអចលវត្ថុត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាមរូបមន្តលិខិតយថាភូត ដោយអាជ្ញាធរមានសមត្ថកិច្ចហើយត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី។ ដូច្នេះយោងតាមច្បាប់ភូមិបាលឆ្នាំ ២០០១នេះវាច្បាស់ណាស់ថា ការបង្កើតកិច្ចសន្យាបញ្ចាំអចលនវត្ថុមួយ ដែលមានសុពលភាព និងអានុភាពអនុវត្តទៅបានដាច់ខាតត្រូវធ្វើឡើងជាលិខិតយថាភូត និងត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី។ ផ្ទុយទៅវិញ នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលកំពុងនៅជាធរមាន ទាក់ទងទៅនឹងការបញ្ចាំអចលនវត្ថុក៏បានកំណត់ឲ្យយកបញ្ញត្តិនៃជំពូកទី ៥ ស្តីពីហ៊ីប៉ូតែកមកអនុវត្តដូចគ្នាផងដែរ[៦] ដោយបានកំណត់ថា ការធ្វើកិច្ចសន្យាបញ្ចាំអចលនវត្ថុជាលិខិតយថាភូត និងចុះបញ្ជីនៅសុរិយោដីវាគ្រាន់តែជាលក្ខខណ្ឌតតាំងចំពោះតតិយជនប៉ុណ្ណោះ វាពុំមែនជាលក្ខខណ្ឌសុពលភាពនោះឡើយ នេះដោយយោងទៅតាមមាត្រា ៨៤៥ នៃក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ ២០០៧។

ទាក់ទងទៅនឹងលក្ខខណ្ឌសុពលភាពនេះផងដែរក្នុងករណីដែលបានបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១ ប៉ុន្តែការបង្កើតនោះ មិនស្របទៅនឹងលក្ខខណ្ឌសុពលភាពដែលកំណត់ដោយច្បាប់ភូមិបាលឆ្នាំ ២០០១ នោះទេ ដូចជាការបង្កើតកិច្ចសន្យាជាលិខិតយថាភូត និងបានប្រគល់វត្ថុទៅឲ្យម្ចាស់បំណុលកាន់កាប់ ប៉ុន្តែមិនបានយកអចលវត្ថុនោះទៅចុះបញ្ជី។ ដូច្នេះតាមរយៈច្បាប់ភូមិបាលឆ្នាំ ២០០១កិច្ចសន្យាបញ្ចាំខាងលើមិនចាត់ទុកថាមានសុពលភាពយកទៅអនុវត្តបាននោះឡើយ។ ផ្ទុយទៅវិញ ការបង្កើតកិច្ចសន្យាបញ្ចាំដែលបានរៀបរាប់ខាងលើ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០១១នៃ មាត្រា ៥៦ កថាខណ្ឌទី១ បានផ្តល់សុពលភាព និងអានុភាពអនុវត្ត ដោយគិតចាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណីនេះតទៅ។ ប៉ុន្តែម្ចាស់បំណុលមិនអាចយកសិទ្ធិនេះទៅជំទាស់នឹងតតិយជន ក្រៅពីកូនបំណុលបានឡើយ។

[៦] មាត្រា ៨៣៩នៃក្រមរដ្ឋប្បវេណី

### ១.១.២.២ លក្ខខណ្ឌជំទាស់នឹងតតិយជន

លក្ខខណ្ឌជំទាស់នឹងតតិយជន គឺជាលក្ខខណ្ឌសំខាន់មួយដែលម្ចាស់បំណុលនៃកិច្ចសន្យាប្រាតិភោគទាំងអស់ ត្រូវគោរពតាម ដើម្បីការពារផលប្រយោជន៍របស់ខ្លួនពីការឈ្លានពានរបស់តតិយជន។ ការបង្កើតកិច្ចសន្យាបញ្ចាំចលវត្ថុ មិនតម្រូវឲ្យមានការចុះបញ្ជីអ្វីនោះទេ គឺគ្រាន់តែតម្រូវឲ្យអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬហៅថា កូនបំណុល ប្រគល់វត្ថុបញ្ចាំទៅឲ្យម្ចាស់សិទ្ធិលើការបញ្ចាំ ឬហៅថា ម្ចាស់បំណុល ដើម្បីកាន់កាប់។ ហេតុដូច្នេះ បើម្ចាស់សិទ្ធិលើការបញ្ចាំ បានកាន់-កាប់វត្ថុបញ្ចាំជានិរន្តន៍នៅក្នុងដៃរបស់ខ្លួន ម្ចាស់សិទ្ធិលើការបញ្ចាំចលនវត្ថុ អាចយកសិទ្ធិនេះទៅជំទាស់នឹងតតិយបាន[៧]។ រីឯការបញ្ចាំអចលនវត្ថុវិញ ច្បាប់តម្រូវឲ្យយកបទប្បញ្ញត្តិស្តីពីហ៊ីប៉ូតែកមកអនុវត្ត។ ដូច្នេះបញ្ញត្តិស្តីពីការតតាំងនៃហ៊ីប៉ូតែក ដែលមានចែងនៅក្នុងមាត្រា ៨៤៥ នៃក្រមរដ្ឋ-ប្បវេណីថ្មីដែលត្រូវយកមកអនុវត្តចំពោះការបញ្ចាំអចលនវត្ថុដែរ។ ហេតុនេះ ដើម្បីបង្កើតសិទ្ធិលើការបញ្ចាំអចលនវត្ថុមួយដែលអាចយកទៅជំទាស់នឹងតតិយជនបាន លុះត្រាតែធ្វើឡើងជាលិខិតយថាភូត និងត្រូវចុះបញ្ជីនៅអង្គភាពសុរិយោដី។

ជាចុងក្រោយ ចំពោះការបញ្ចាំសិទ្ធិលើបំណុលដែលមានកំណត់ឈ្មោះ ដើម្បីអាចឲ្យម្ចាស់សិទ្ធិលើការបញ្ចាំអាចយកសិទ្ធិលើបំណុលរបស់ខ្លួនទៅជំទាស់នឹងកូនបំណុលកូនបំណុលទី៣ និងតតិយផ្សេងទៀតលុះត្រាបានជូនដំណឹងអំពីការបង្កើតសិទ្ធិលើការបញ្ចាំដល់កូនបំណុលទី៣ ឬមានការយល់ព្រមពីកូនបំណុលទី៣ ដោយធ្វើឡើងដោយមានជាលិខិតការបរិច្ឆេទស្កាពរ[៨]។

### ១.១.៣ កម្មវត្ថុនៃកិច្ចសន្យាបញ្ចាំ

កម្មវត្ថុ គឺជាគោលបំណងនៃកិច្ចសន្យា ដែលត្រូវបានបង្កើតឡើងអាស្រ័យនៅតាមឆន្ទៈរបស់គូភាគី។ ចំពោះកិច្ចសន្យាបញ្ចាំ កម្មវត្ថុរបស់វាត្រូវបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ២០០៧ នៃមាត្រា ៨១៦បានចែងអំពីនិយមន័យនៃសិទ្ធិលើការបញ្ចាំ ដែលបញ្ជាក់ថា ម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់វត្ថុដែលទទួលបានពីកូនបំណុល។ ពាក្យថាវត្ថុត្រូវប្រើជាកម្មវត្ថុលើការបញ្ចាំ ប៉ុន្តែតាមរយៈមាត្រាខាងលើនេះវាពុំបញ្ជាក់អត្ថន័យឲ្យស៊ីជម្រៅ និងច្បាស់លាស់នោះទេ។ មួយទៀត ទោះបីជា

[៧] មាត្រា ៨២៩នៃក្រមរដ្ឋប្បវេណី ២០០៧

[៨] មាត្រា៨៤១នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ការប្រើពាក្យថាវត្ថុ នៅក្នុងមាត្រា ៨១៦ ខាងលើនេះក៏ដោយ ក៏ពុំមានន័យថា សិទ្ធិមិនអាចក្លាយជាកម្មវត្ថុនៃការបញ្ចាំនោះឡើយ។

លើសពីនេះទៅទៀត វត្ថុឬសិទ្ធិទាំងឡាយដែលមិនអាចធ្វើអនុប្បទានបាន មិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សបានឡើយ[៩]។ ដោយហេតុថាកិច្ចសន្យាប្រាតិភោគប្រត្យក្ស គឺដើម្បីធានានូវការសងបំណុលទៅដល់ម្ចាស់បំណុលទៅដល់ម្ចាស់បំណុល ប្រសិនបើបំណុលមិនត្រូវបានសងនោះទេ វត្ថុដែលត្រូវជាកម្មវត្ថុនៃការបញ្ចាំនឹងត្រូវចាត់ចែងប្តូរជាប្រាក់ ហើយម្ចាស់បំណុលនឹងទទួលការសងពីប្រាក់នោះ ដោយមានអាទិភាពជាងម្ចាស់បំណុលផ្សេងទៀត។ ហេតុដូច្នេះវត្ថុឬសិទ្ធិ ដែលមិនអាចយកទៅប្តូរជាប្រាក់ដោយសារមិនអាចធ្វើអនុប្បទានបាន វានឹងមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគបានឡើយ យោងទៅលើក្រមរដ្ឋប្បវេណីថ្មី កម្មវត្ថុ នៃសិទ្ធិលើការបញ្ចាំអាចជាចលនវត្ថុ (១.១.៣.១) ឬអចលនវត្ថុ(១.១.៣.២) និងការបញ្ចាំសិទ្ធិ (១.១.៣.៣)។ តើកម្មវត្ថុនៃការបញ្ចាំទាំងបីខាងលើនេះ មានអត្ថន័យយ៉ាងដូចម្តេច?

### ១.១.៣.១ ការបញ្ចាំចលនវត្ថុ

ជាទូទៅកម្មវត្ថុនៃកិច្ចសន្យាបញ្ចាំចលនវត្ថុគឺជាវត្ថុដែលកូនបំណុលបានយកមកដាក់បញ្ចាំដើម្បីធានាបំណុលរបស់ខ្លួន។ ចំណែកឯពាក្យថា ចលនវត្ថុនោះសម្តៅទៅវត្ថុ ឬទ្រព្យទាំងឡាយណាដែលអាចកម្រើកបាន អាចលើកដាក់បាន និងដឹកពីកន្លែងមួយទៅកន្លែងមួយទៀតបានមានដូចជាឡាន ម៉ូតូ ជាដើម។នេះបើយោងទៅតាមសេចក្តីពន្យល់របស់វចនានុក្រមរបស់សម្តេចសង្ឃជួន ណាត។ ចំណែកឯក្រមរដ្ឋប្បវេណីវិញ ចលនវត្ថុ គឺសម្តៅទៅលើវត្ថុក្រៅពីអចលនវត្ថុ[១០]។ ម្យ៉ាងវិញទៀត ចលនវត្ថុដែលដាក់បញ្ចាំត្រូវតែជាកម្មសិទ្ធិរបស់កូនបំណុលឬ ប្រសិនបើកូនបំណុលជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ឬជាកម្មសិទ្ធិរបស់តតិយជន ប្រសិនបើតតិយជននោះជាអ្នកបង្កើតសិទ្ធិលើការបញ្ចាំ ដើម្បីធានាបំណុលអ្នកដទៃ។ ចាងនេះទៅទៀត ចលនវត្ថុនោះត្រូវតែជាចលនវត្ថុដែលអាចរឹបអូសបាន។ ឧទាហរណ៍ ដូចជា ឡាន ម៉ូតូ ទូរទស្សន៍ រួមបញ្ចូលទាំងទឹកប្រាក់ផងដែរ។

ឧទាហរណ៍ លោក ក បានយករថយន្តដែលជាកម្មសិទ្ធិរបស់ខ្លួន មកដាក់បញ្ចាំនឹងលោក ខ ដើម្បីធានាបំណុលរបស់ ៣០០០ ដុល្លារសហរដ្ឋអាមេរិក។ ដូច្នេះកិច្ចសន្យានេះត្រូវបានបង្កើតឡើង

[៩] មាត្រា ៧៦៨ នៃក្រមរដ្ឋប្បវេណី២០០៧

[១០] មាត្រា ១២០ នៃក្រមរដ្ឋប្បវេណី ២០០៧

ក្រោយពីពេលដែលលោក ខ បានទទួលកាន់កាប់រថយន្តនោះ និងក្រោយពីលោក ខ បានប្រគល់ប្រាក់ទៅឲ្យលោក ក។

### ១.១.៣.២ ការបញ្ចាំអចលនវត្ថុ

ការបញ្ចាំអចលនវត្ថុមានចែងនៅក្នុងរដ្ឋប្បវេណីពីមាត្រា ៨៣៩ដល់ មាត្រា៨៣៩ និងបានឲ្យនិយមន័យនៃពាក្យអចលនវត្ថុ សម្តៅទៅលើដីធ្លី ឬវត្ថុដែលជាប់នឹងដី ដែលមិនអាចផ្លាស់ប្តូរទីកន្លែងបានមានដូចជាអគារ សំណង់ រុក្ខជាតិ និងដំណាំដាំដុះជាដើម។ បើតាមច្បាប់ភូមិបាលបានបែងចែកអចលនវត្ថុជា បីប្រភេទ មានអចលនវត្ថុពីកំណើត អចលនវត្ថុភ័ព្វព្រេងវាសនា និងអចលនវត្ថុតាមការកំណត់របស់ច្បាប់[១១]។

អចលនវត្ថុ ពីកំណើតជាវត្ថុទាំងឡាយណាដែលកើតពីធម្មជាតិ ដូចជាព្រៃឈើ ដីកាប់រាន ដីដាំដុះ ដីទុកទំនេរ ឬមិនដាំដុះ ដីលិចទឹកដោយទឹកនៅនឹង ឬទឹកហូរ សំណង់ឬ ការរៀបចំទាំងឡាយដែលស្ថិតនៅជាប់មួយកន្លែង កើតឡើងដោយអំពើរបស់មនុស្ស ហើយមិនអាចរំកិលបានផ្លាស់ប្តូរកន្លែងបាន។ ចំណែកឯវត្ថុតាមភ័ព្វវាសនា មានវត្ថុដែលជាប់នឹងដី ឬបញ្ចូលជាមួយសំណង់ទាំងឡាយដែលមិនអាចបំបែកបានដោយមិនធ្វើឲ្យមានការខូចខាត ឬមិនដូរសភាពដើមដូចជាដើមឈើ ឬឧបករណ៍តែងលម្អជាដើម។ ជាចុងក្រោយ គឺចលនវត្ថុទាំងឡាយដែលបានកំណត់ដោយច្បាប់ជាអចលនវត្ថុ។ ឧទាហរណ៍ ដូចជានាវាជាដើម។

ទោះបីជាច្បាប់ភូមិបាល ឆ្នាំ២០០១ បានបែងចែកអចលនវត្ថុជាបីប្រភេទក៏ដោយ ក៏នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ជំពូកទី៤ ផ្នែកទី៣ ការបញ្ចាំអចលនវត្ថុ គឺផ្តោតសំខាន់តែទៅលើអចលនវត្ថុជាដីធ្លី និងវត្ថុជាប់នៅលើដី ដូចជាផ្ទះ អគារ និងសំណង់ជាដើម។

### ១.១.៣.៣ ការបញ្ចាំសិទ្ធិ

ការបញ្ចាំសិទ្ធិ គឺជាសញ្ញាណមួយថ្មីដែលមិនបានចែងនៅក្នុងក្រមរដ្ឋប្បវេណីចាស់ ឬនៅក្នុងបទប្បញ្ញត្តិផ្សេងៗទៀតស្តីពីការបញ្ចាំឡើយ។ ដូច្នេះដោយមើលឃើញថា ការបញ្ចាំសិទ្ធិគឺជាសញ្ញាណមួយថ្មីសម្រាប់កម្ពុជា ហើយសញ្ញាណត្រូវបានគេប្រើយ៉ាងទូលំទូលាយ នៅបណ្តាប្រទេសអភិវឌ្ឍន៍ជាច្រើន ជាពិសេសទៅទៀតវាជាផ្នែកមួយដែលជំរុញកំណើនសេដ្ឋកិច្ចផងនោះ

[១១] មាត្រា ២នៃច្បាប់ភូមិបាល ២០០១

ទើបការបញ្ចាំសិទ្ធិត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ក្នុងមាត្រា៨៥៩ ដល់មាត្រា ៨៩២។

ដូចដែរយើងបានបកស្រាយរួចហើយថាការបញ្ចាំ អាចត្រូវបានធ្វើឡើងក្រោមរូបភាព បីយ៉ាងគឺការបញ្ចាំចលនវត្ថុ ការបញ្ចាំអចលនវត្ថុ និងការបញ្ចាំសិទ្ធិ។ នៅក្នុងមាត្រា ៨៤០ នៃក្រមរដ្ឋប្បវេណី បានចែងថាសិទ្ធិលើការបញ្ចាំអាចបង្កើតបាន មិនត្រឹមតែលើវត្ថុប៉ុណ្ណោះទេ ថែមទាំងសិទ្ធិលើទ្រព្យសម្បត្តិ ដូចជាសិទ្ធិលើបំណុលក៏អាចក្លាយជាកម្មវត្ថុនៃការបញ្ចាំផងដែរ។ ការបញ្ចាំចលនវត្ថុឬអចលនវត្ថុ គឺត្រូវយកចលនវត្ថុ ឬអចលនវត្ថុនោះទៅប្រគល់ឲ្យម្ចាស់សិទ្ធិលើការបញ្ចាំកាន់កាប់។ ប៉ុន្តែការបញ្ចាំសិទ្ធិ ខុសពីការបញ្ចាំចលនវត្ថុ និងអចលនវត្ថុ ពីព្រោះថាសិទ្ធិ ជាវត្ថុអរូបិយ ដែលយើងមិនអាចកាន់ មិនអាចប៉ះ និងមិនអាចមើលឃើញបានឡើយ ដូច្នេះតើយើងអាចបង្កើតការបញ្ចាំសិទ្ធិ ចាំបាច់ត្រូវប្រគល់វត្ថុអ្វីជាចាំបាច់ ដើម្បីធ្វើឲ្យកិច្ចសន្យាបញ្ចាំសិទ្ធិមានអានុភាព?

ការបញ្ចាំសិទ្ធិ សម្តៅទៅលើការដែលកូនបំណុលយកសិទ្ធិលើបំណុលរបស់ខ្លួនដែលមានចំពោះកូនបំណុលទី ៣ ទៅដាក់បញ្ចាំឲ្យម្ចាស់សិទ្ធិលើការបញ្ចាំរបស់ខ្លួន ដើម្បីធានានូវការសងបំណុលនោះ។ ក្រៅពីសិទ្ធិលើបំណុល នៅមានសិទ្ធិអ្នកនិពន្ធ និងកម្មសិទ្ធិបញ្ញា ក៏អាចក្លាយជាកម្មវត្ថុនៃការបញ្ចាំសិទ្ធិនេះផងដែរ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្ន ពុំទាន់ឃើញមានការប្រើប្រាស់សញ្ញាណនេះនៅឡើយទេដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋទូទៅអំពីសិទ្ធិលើបំណុលក៏ដូចជាកម្មសិទ្ធិបញ្ញាផ្សេងទៀតនៅមានកម្រិត ព្រមជាមួយនឹងសញ្ញាណនៃការបញ្ចាំសិទ្ធិនេះថ្មីផងនោះទើបការបញ្ចាំសិទ្ធិពុំសូវត្រូវបានគេស្គាល់ និងយកមកអនុវត្តពីសំណាក់ប្រជាពលរដ្ឋទូទៅ គ្រឹះស្ថានហិរញ្ញវត្ថុ នៅឡើយទេក្នុងពេលបច្ចុប្បន្ន។

ឧទាហរណ៍ លោក ក បានទៅខ្ចីប្រាក់ពីលោក ខ ចំនួន ៥០០០ដុល្លារ ដោយលោក ខ ត្រូវការប្រើប្រាស់ប្រាក់ជាបន្ទាន់ ហើយក៏មិនទាន់ដល់ពេលកំណត់ត្រូវសងផងនោះ។ លោក ខ ក៏សម្រេចចិត្តទៅខ្ចីប្រាក់ពីលោក គ ចំនួន២០០០ ដុល្លារ។ ក្នុងករណីនេះប្រសិនបើលោក ខ មិនមានទ្រព្យសម្បត្តិអ្វីដើម្បីដាក់បញ្ចាំឲ្យលោក គ ដើម្បីធានាបំណុលនោះទេ លោក ខ អាចយកសិទ្ធិលើបំណុលរបស់ខ្លួនជាមួយនឹងលោក ក ចំនួន ៥០០០ដុល្លារនោះទៅដាក់បញ្ចាំបាន។ នេះជាការយកសិទ្ធិលើបំណុលទៅដាក់បញ្ចាំ។

## ១.២ ប្រតិបត្តិការបញ្ចាំនៅក្រុមហ៊ុនវីប្រេាប្រថីធី

ក្រុមហ៊ុនវីប្រេ្ហាប្រថីធី ជាក្រុមហ៊ុនមួយ ដែលបានដាក់បម្រើសេវាបញ្ចាំ និងប្រាតិភោគដោយអានុប្បទាន ដែលបច្ចុប្បន្នកំពុងបម្រើសេវារបស់ខ្លួន ទៅដល់អតិថិជនភាគច្រើនដែរ។ អតិថិជនអាចទទួលបានសេវា ដោយត្រូវបំពេញទៅតាមលក្ខន្តិកៈដែលក្រុមហ៊ុនបានកំណត់ ដែលមានជាដំណាក់កាល។

### ១.២.១ ការព្រមព្រៀងលើសេវា

ជាបឋមអតិថិជនទាំងអស់ត្រូវបានទាមទារឲ្យឆ្លងកាត់នូវការសម្ភាសន៍ជាមួយនឹងភ្នាក់ងារក្រុមហ៊ុន ។ ដោយភ្នាក់ងារក្រុមហ៊ុននឹងផ្តល់ពត៌មានដែលជាគោលការណ៍របស់ក្រុមហ៊ុនដែលត្រូវព្រមព្រៀងគ្នា ក៏ដូចជាប្រមូលពត៌មានជាក់លាក់ពីអតិថិជនមុនឈានដល់ការផ្តល់សេវា។ អតិថិជនអាចសួរលំអិតអំពីគោលការណ៍ទាំងនោះបាន ព្រមទាំងត្រូវធ្វើការសម្រេចចិត្តថាត្រូវទទួលយក ឬមិនទទួលនូវសេវានេះ។ នៅក្នុងដំណាក់កាលនេះត្រូវធ្វើការព្រមព្រៀងទៅលើចំណុចមួយចំណុចដូចខាងក្រោម៖

#### ១.២.១.១ ប្រភេទទ្រព្យ

ចំពោះប្រតិបត្តិការបញ្ចាំរបស់ ក្រុមហ៊ុនវីប្រេ្ហាប្រថីធី គឺអនុវត្តតែទៅលើអចលនទ្រព្យដែលស្ថិតនៅក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះមានដូចជា ផ្ទះ និងដី ។ ជាគោលការណ៍អចលនទ្រព្យទាំងនោះត្រូវមានបញ្ជាក់កម្មសិទ្ធិជាទម្រង់យថាភូត ថា អចលនទ្រព្យនោះគឺពិតជាកម្មសិទ្ធិរបស់កូនបំណុល ឬជាកម្មសិទ្ធិរបស់តតិយជនដែលមានការឯកភាពគ្នារួចថានឹងដាក់អចលនទ្រព្យនោះដើម្បីនឹងធានាលើបំណុលដែលកូនបំណុលផ្ទាល់ដែលមានបំណងចង់ខ្ចី ។ លិខិតទាំងនោះមានតែ ២ ប្រភេទ ប៉ុណ្ណោះ គឺ ទម្រង់ លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង វិញ្ញាណបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងត្រូវភ្ជាប់មកជាមួយនូវលិខិតទិញ លក់នៅអចលនទ្រព្យនោះផងដែរដើម្បីបង្ហាញថាអចលនទ្រព្យនោះគឺពិតជាកម្មសិទ្ធិផ្ទាល់ពិតប្រាកដ ។

### ១.២.១.២ ចំនួនប្រាក់កម្ចី និងរយៈពេលនៃការបញ្ចាំ

ជាក់ស្តែងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានកំណត់ ថាចំនួនប្រាក់កម្ចីគឺអតិបរមា ២០,០០០,០០០រៀលប៉ុណ្ណោះ[១២] ព្រមទាំងរយៈពេលនៃការដាក់បញ្ចាំគឺមានតែរយៈ ៤ខែប៉ុណ្ណោះ[១៣] ដូច្នេះប្រតិបត្តិការបញ្ចាំនៅក្នុងក្រុមហ៊ុនគឺត្រូវតែស្របទៅនឹងការកំណត់នេះ ពោលគឺ ក្រុមហ៊ុនពុំអាចផ្តល់ប្រាក់កម្ចីលើស ២០,០០០,០០០រៀល ឬប្រហែល៥០០០ដុល្លារអាមេរិកឡើយ និងរយៈ-ពេលតែ ៤ខែប៉ុណ្ណោះ ដោយគោរពតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ១.២.១.៣ សោហ៊ុយលើសេវា

ជាគោលការណ៍ក្រុមហ៊ុនជាអ្នករត់ការណ៍ទាំងស្រុងនៅក្នុងដំណើរការកិច្ចសន្យា មានដូចជា សេវាមេធាវី ការធ្វើដំណើរ ក៏ដូចជាការបញ្ជាក់លិខិតផ្សេងៗក្នុងទម្រង់យថាភូត គឺតែងតែត្រូវការចំណាយនូវថវិកាមួយចំនួន ជាមិនខាន។ ដោយហេតុនេះហើយក្រុមហ៊ុនទាមទារត្រូវតែដកថ្លៃសេវាមួយចំនួនពីអតិថិជន អតិបរមា ១០ភាគរយនៃចំនួនប្រាក់កម្ចី សម្រាប់ដំណើរប្រតិបត្តិការខាងលើ ដោយអាស្រ័យលើការព្រមព្រៀងរបស់ភាគីទាំងពីរ។

### ១.២.១.៤ អត្រាការប្រាក់

បន្ទាប់ពីអតិថិជនបានព្រមព្រៀងលើសេវាហើយកូនបំណុលត្រូវមានកាតព្វកិច្ចបង់ការប្រាក់ទៅតាមអត្រាការប្រាក់របស់ក្រុមហ៊ុនដែលបានកំណត់ជាប្រចាំខែរហូតដល់បំណុលត្រូវបានទូទាត់សងគ្រប់ចំនួនតាមការព្រមព្រៀងដូចមានចែងក្នុងកិច្ចសន្យា។ ជាការពិតណាស់ផលចំណេញរបស់ក្រុមហ៊ុនគឺមួយភាគធំបានមកពីការប្រាក់នេះហើយ ជាក់ស្តែងក្រុមហ៊ុនវីប្រេក្លាប្រថឹធីបានកំណត់អាត្រាការប្រាក់អតិបរិមា ១.៧ ភាគរយនៃចំនួនប្រាក់កម្ចីសរុប។ ដោយឡែក ចំពោះ ការប្រាក់ខែដំបូងត្រូវដកនៅដើមចំនួន១ខែ ជាមុន ក្នុងករណីនេះបើទោះបីជាកូនបំណុលមានបំណងចង់សងបំណុលក្នុងអំឡុងខែដំបូងមុនកំណត់គឺ ពុំអាចដកការប្រាក់ខែដំបូងនោះបានឡើយ។ដោយឡែកចំពោះខែបន្ទាប់កូនបំណុលត្រូវបង់ការប្រាក់នៅចុងខែតាមកាលបរិច្ឆេទជាកំហិត។ក្នុងករណីដែលអតិថិជនបានបង់ការប្រាក់យឺតជាងថ្ងៃកំណត់រយៈពេល ៣ថ្ងៃ នោះអតិថិជននឹងត្រូវពិន័យបន្ថែម

[១២] ចំណុចទី២០ ប្រការ១០ នៃប្រកាសស្តីពី ការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មប្រាតិភោគដោយអនុប្បទាន

[១៣] ចំណុចទី៤ នៃលក្ខខណ្ឌរបស់កិច្ចសន្យាបញ្ចាំរបស់ក្រសួងសេដ្ឋកិច្ច។

លើការប្រាក់ គឺចំនួន៥ភាគរយនៃការចំនួនការប្រាក់សរុប លើកលែងតែមានករណីពិសេសដូចជាថ្ងៃឈប់សម្រាកបុណ្យជាតិណាមួយ ឬការអាក់ខានណាមួយរបស់ក្រុមហ៊ុនប៉ុណ្ណោះ។

#### ១.២.១.៥ ឯកសារដែលត្រូវភ្ជាប់

ដើម្បីដាក់បញ្ចាំនៅក្រុមហ៊ុនវីប្រ៊្ហោប្រចឹធី អតិថិជនត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណរបស់បុគ្គលដែលពាក់ព័ន្ធច្បាប់ដើម។
- សៀវភៅស្នាក់នៅច្បាប់ដើម។
- លិខិតបញ្ជាក់កម្មសិទ្ធិលើអចលនវត្ថុដែលត្រូវដាក់ធានា។

#### ១.២.១.៦ សេវារំលស់លើបំណុលមុនរបស់កូនបំណុល

ក្នុងករណីដែលអតិថិជនដែលមានបំណងចង់ដាក់បញ្ចាំនៅក្រុមហ៊ុនវីប្រ៊្ហោប្រចឹធី ប៉ុន្តែអតិថិជននោះបានជាប់បំណុលនៅធនាគារ ឬ មីក្រូហិរញ្ញវត្ថុ ឬក្រុមហ៊ុនឯកជនណាមួយ នោះក្រុមហ៊ុនវីប្រ៊្ហោប្រចឹធី ក៏មានសេវាកម្មបន្ថែមក្នុងការរំលស់បំណុលជំនួសអតិថិជន ដោយគិតតម្លៃសេវាអតិបរមា ៣ ភាគរយនៃចំនួនប្រាក់បំណុលដែលជាប់នៅស្ថាប័ននោះផងដែរ។

### ១.២.២ ការបំពេញបែបបទក្នុងការចុះកិច្ចសន្យា និងការដោះបំណុល

បន្ទាប់ពីអតិថិជនបានព្រមព្រៀងលើលក្ខន្តិកៈរបស់ក្រុមហ៊ុនហើយ ព្រមទាំងមានភ្ជាប់សំណុំឯកសារគ្រប់គ្រាន់តាមការកំណត់របស់ក្រុមហ៊ុនហើយ នោះអតិជនត្រូវបំពេញនូវកិច្ចសន្យាមួយចំនួនជាមួយនឹងក្រុមហ៊ុន ដែលក្នុងនោះអាចមាន ២ករណី ដែលករណីទី១ អតិថិជនមានតែ លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង (១.២.២.១) និងករណីទី២ អតិថិជនមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (១.២.២.២)។

#### ១.២.២.១ ករណីអតិថិជនមាន លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង (ប្លង់ទន់)

ក្នុងករណីនេះអតិថិជនត្រូវបំពេញកិច្ចសន្យាមួយចំនួនជាមួយក្រុមហ៊ុន ដែលមានដូចជាកិច្ចសន្យាជាទម្រង់ឯកជនជាមួយក្រុមហ៊ុន និងកិច្ចសន្យាជាទម្រង់យថាភូតដែលមានការទទួលដឹងលឺពីអាជ្ញាធរដែនដី។

### ក.កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

ដើម្បីទទួលបានប្រាក់កម្ចីកូនបំណុលត្រូវធ្វើកិច្ចសន្យាមួយ ជាមួយក្រុមហ៊ុនេះវីហ្គោប្រថិធី គឺកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់។ ក្នុងកិច្ចសន្យានេះត្រូវបានកំណត់អំពីចំនួនប្រាក់កម្ចី[១៤] ដែលបានព្រមព្រៀងគ្នាហើយ និងមានកំណត់អាត្រាការដែលកូនបំណុលត្រូវមានកាតព្វកិច្ចត្រូវបង់ប្រចាំខែបន្ទាប់ពីកិច្ចសន្យានេះមានអានុភាព ។ ដោយឡែកក្រុមហ៊ុនវីហ្គោប្រថិធីកំណត់ឲ្យកូនបំណុលអាចពន្យាពេលនៃការបង់ការប្រាក់តែរយៈពេល ៣ថ្ងៃប៉ុណ្ណោះបន្ទាប់ពីថ្ងៃកំណត់ត្រូវបង់ការប្រាក់ តែបើពុំដូចនោះទេ កូនបំណុលត្រូវបង់ប្រាក់ពិន័យចំនួន ៥ ភាគរយនៃតម្លៃការប្រាក់។

### ខ.កិច្ចសន្យាបញ្ចាំអចលនវត្ថុ

កិច្ចសន្យាបញ្ចាំអចនលវត្ថុនេះ គឺជាកិច្ចកិច្ចសន្យាមួយដែលបង្ហាញថាកូនបំណុលបានព្រមព្រៀងថាដាក់បញ្ចាំនូវអចលនវត្ថុរបស់ខ្លួនមកឲ្យក្រុមហ៊ុនកាន់កាប់ជាបណ្ដោះអាសន្នលើអចលន-វត្ថុនោះរហូតដល់ទូទាត់បំណុលសព្វគ្រប់ពោលគឺកូនបំណុលពុំមានសិទ្ធិចាត់ចែងលើវត្ថុបញ្ចាំនោះឡើយដូចជាការលក់ដូរ បញ្ចាំ ជួល ធ្វើប្រទានកម្ម ឬធ្វើសន្តតិកម្មជាដើម ។ ដោយឡែកនៅក្នុងប្រការ ៦នៃកិច្ចសន្យានេះបានអនុញ្ញាតឲ្យកូនបំណុលមានសិទ្ធិប្រើប្រាស់លើអចលនវត្ថុនោះបានក្នុងករណីដែលមានការស្នើសុំពីកូនបំណុល។ កិច្ចសន្យានេះត្រូវធ្វើចំនួន ៣ច្បាប់ ដែលត្រូវតម្កល់សាលាសង្កាត់ដែលអចនវត្ថុស្ថិតនៅ ១ ច្បាប់ ក្រុមហ៊ុន ១ ច្បាប់ និងកូនបំណុល ១ច្បាប់។

### គ. កិច្ចសន្យាបញ្ចាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តាមរយៈការតម្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះក្រុមហ៊ុនក៏ត្រូវធ្វើកិច្ចសន្យាបញ្ចាំដែលបានកំណត់ដោយក្រសួងនេះចំនួន ២ច្បាប់ហើយត្រូវក្រុមហ៊ុនជាអ្នកទុក ១ ច្បាប់ និងកូនបំណុលទុក១ច្បាប់។

### ឃ.ការផ្ទេរកម្មសិទ្ធិនៅសមត្ថកិច្ចដែនដី

នៅក្នុងករណីអតិថិជនមានតែ លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង នោះក៏ត្រូវធ្វើការផ្ទេរការកាន់កាប់ ពីកម្មសិទ្ធិករ ទៅឲ្យតំណាងក្រុមហ៊ុនដោយត្រូវមានការព្រមព្រៀងពីភាគីកូនបំណុលបើជាកម្មសិទ្ធិករ ប៉ុន្តែបើកម្មសិទ្ធិករជាតតិយជន ភាគីត្រូវជាតតិយជននោះក្នុងការផ្ដិតមេដៃចំពោះតំណាងក្រុមហ៊ុន ដែលត្រូវធ្វើឡើងចំពោះមុខអាជ្ញាធរដែនដីមាន លោកមេភូមិ

[១៤] ប្រការ ២នៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

ស្មៀនឃុំ លោកចៅសង្កាត់ ដើម្បីជាសក្ខីភាព។ ដោយឡែកបើប្រាក់បំណុលមានចំនួនច្រើនអាចធ្វើឡើងទៅដល់សាលាខណ្ឌបន្ថែមទៀតដោយមានការបញ្ជាក់ពីលោកចៅហ្វាយខណ្ឌទៀតផង ដើម្បីធានាសិទ្ធិ កាតព្វកិច្ចនោះឲ្យបានកាន់តែរឹងមាំ។ នៅក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់នេះត្រូវបរិយាយក្នុងអត្ថន័យថា ការផ្ទេរសិទ្ធិត្រូវធ្វើឡើងនៅក្រោមទម្រង់ជាការបញ្ចាំ ពោលគឺកូនបំណុលត្រូវដាក់ទ្រព្យនោះបណ្តោះអាសន្នមកឲ្យក្រុមហ៊ុនកាន់កាប់តាមរយៈការបញ្ចាំ។

**ខ. ការកាន់កាប់សំណុំឯកសារ**

បន្ទាប់ពីកូនបំណុល និងតំណាងក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយគ្នាហើយនោះ កូនបំណុលត្រូវប្រគល់ឯកសារមួយចំនួនទៅឲ្យក្រុមហ៊ុនជាអ្នកថែរក្សាឯកសារ មានដូចជាសៀវភៅគ្រួសារច្បាប់ដើម អត្តសញ្ញាណប័ណ្ណបុគ្គលដែលពាក់ព័ន្ធ លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីនិងផ្ទះសម្បែងរវាងកម្មសិទ្ធិករដំបូងមកឲ្យកូនបំណុល ឬតតិយជនដែលបានដាក់បញ្ចាំច្បាប់ដើម និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងរវាងកូនបំណុល ឬតតិយជន មកឲ្យក្រុមហ៊ុន ច្បាប់ដើម ។ ចំណែកឯកិច្ចសន្យាដទៃទៀតដូចមានរៀបរាប់ខាងលើត្រូវក្រុមហ៊ុនជាអ្នកកាន់កិច្ចសន្យាទាំងអស់១ ច្បាប់ និង ១ច្បាប់ទៀតកូនបំណុលជាអ្នកកាន់ ។

**ច. ការដោះបំណុល**

នៅពេលដែលកូនបំណុលបានសងបំណុលគ្រប់ចំនួនហើយ នោះភ្នាក់ងារក្រុមហ៊ុននឹងត្រូវរៀបចំឯកសារមួយចំនួនដូចខាងក្រោមៈ

**ច.១ លិខិតបញ្ជាក់ការរួចបំណុល**

ក្រុមហ៊ុននឹងចេញជាលិខិតបញ្ជាក់ពីការរួចបំណុលដោយមានបញ្ជាក់ថាកូនបំណុលបានសងបំណុលគ្រប់ចំនួនហើយ ហើយបន្ទាប់ពីចេញលិខិតនេះ រាល់ការខូចខាតបាត់បង់ផ្សេងៗរបស់កូនបំណុលពុំពាក់ព័ន្ធនឹងក្រុមហ៊ុនឡើយ ដោយធ្វើឡើងចំនួន ៣ច្បាប់( ១ច្បាប់តម្កល់នៅសាលា-សង្កាត់ដែលទ្រព្យនោះតាំងនៅ ១ ច្បាប់ក្រុមហ៊ុនជាអ្នកកាន់ និង ១ច្បាប់ទៀតកូនបំណុលជាអ្នកកាន់។

**ច.២ ការដោះបំណុលនៅសមត្ថកិច្ចដែនដី**

ការដោះបំណុល គឺក្រុមហ៊ុនត្រូវតម្កល់លិខិតបញ្ជាក់ការរួចបំណុល ១ច្បាប់ នៅសាលាសង្កាត់ និង ភ្ជាប់ជាមួយលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង រវាងកម្មសិទ្ធិករដំបូងមកឲ្យកូនបំណុល ឬតតិយជនដែលបានដាក់បញ្ចាំច្បាប់ដើម នោះមន្ត្រីសង្កាត់ដែលមានសមត្ថកិច្ចនឹងធ្វើការលុបចោលនៅលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងក្រោយដែលបានធ្វើរវាងកូនបំណុល ឬតតិយជន មកឲ្យក្រុមហ៊ុន ចោលហើយលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងនោះពុំមានអានុភាពទៀតឡើយ។ មន្ត្រីសង្កាត់ នឹងប្រគល់លិខិតចាស់ទៅឲ្យកូនបំណុលវិញ ដែលកូនបំណុលអាចប្រើប្រាស់លិខិតផ្ទេរសិទ្ធិចាស់នោះជាធម្មតាបាន។

**១.២.២.២ ករណីអតិថិជនមានប័ណ្ណសម្គាល់កម្មសិទ្ធិ( ប្លង់រឹង)**

ក្នុងករណីនេះកិច្ចសន្យាដែលត្រូវធ្វើនោះមានលក្ខណៈខុសគ្នានឹងករណីដែលអតិថិជនមានតែលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងដោយត្រូវបំពេញនូវកិច្ចសន្យាដូចខាងក្រោមៈ

**ក. កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់**

ដូចក្នុងករណីដែលកូនបំណុលមានតែលិខិតផ្ទេរសិទ្ធិកានើកាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងដែរ កូនបំណុលត្រូវធ្វើកិច្ចសន្យាមួយ ជាមួយក្រុមហ៊ុនេះវីប្រ្កោប្រចីធី គឺកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់។ ក្នុងកិច្ចសន្យានេះត្រូវបានកំណត់អំពីចំនួនប្រាក់កម្ចី[១៥] ដែលបានព្រមព្រៀងគ្នាហើយ និងមានកំណត់អាត្រាការដែលកូនបំណុលត្រូវមានកាតព្វកិច្ចត្រូវបង់ប្រចាំខែបន្ទាប់ពីកិច្ចសន្យានេះមានអានុភាព។ ដោយឡែកក្រុមហ៊ុនវីហ្គោប្រចីធីកំណត់ឲ្យកូនបំណុលអាចពន្យាពេលនៃការបង់ការប្រាក់តែរយៈពេល ៣ថ្ងៃប៉ុណ្ណោះបន្ទាប់ពីថ្ងៃកំណត់ត្រូវបង់ការប្រាក់ តែបើពុំដូចនោះទេ កូនបំណុលត្រូវបង់ប្រាក់ពិន័យចំនួន ៥ ភាគរយនៃតម្លៃការប្រាក់។

**ខ. កិច្ចសន្យាបញ្ចាំអចលនវត្ថុ**

កិច្ចសន្យាបញ្ចាំអចនលវត្ថុនេះ បានដាក់កាតព្វកិច្ចឲ្យកូនបំណុលត្រូវដាក់បញ្ចាំនូវអចលនវត្ថុរបស់ខ្លួនមកឲ្យក្រុមហ៊ុនកាន់កាប់ជាបណ្តោះអាសន្នលើអចលនវត្ថុនោះរហូតដល់ទូទាត់បំណុល

[១៥] ប្រការ ២នៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

សព្វគ្រប់ពេលគឺកូនបំណុលពុំមានសិទ្ធិចាត់ចែងលើវត្ថុបញ្ចាំនោះឡើយដូចជាការលក់ដូរ បញ្ចាំជួល ធ្វើប្រទានកម្ម ឬធ្វើសន្តតិកម្មជាដើម ។ ដោយឡែកនៅក្នុងប្រការ ៦នៃកិច្ចសន្យានេះបាន អនុញ្ញាតឲ្យកូនបំណុលមានសិទ្ធិប្រើប្រាស់លើអចលនវត្ថុនោះបានផងដែរ ក្នុងករណីដែលមានការស្នើសុំពីកូនបំណុល។ កិច្ចសន្យានេះត្រូវធ្វើចំនួន ៣ច្បាប់ ដែលត្រូវតម្កល់សាលាសង្កាត់ដែលអចលនវត្ថុនោះស្ថិតនៅ ១ ច្បាប់ ក្រុមហ៊ុន ១ ច្បាប់ និងកូនបំណុល ១ច្បាប់។

**គ.កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ**

ចំពោះករណីអតិថិជនដែលមានប័ណ្ណបញ្ជាក់កម្មសិទ្ធិ ជាបឋមដើម្បីចុះបន្ទុកលើការបញ្ចាំ តំណាងក្រុមហ៊ុន និងកូនបំណុលត្រូវព្រមព្រៀងគ្នា និងផ្តិតមេដៃលើពាក្យសុំចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំ នឹងត្រូវស្នើសុំទៅលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ហើយត្រូវភ្ជាប់ជាមួយនូវកិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំដោយមានការឯកភាពពីភាគីនីមួយៗ ព្រមទាំងមានការបញ្ជាក់ពីអាជ្ញាធរសង្កាត់ផងដែរ និងភ្ជាប់ជាមួយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ។

នៅពេលដែលសំណុំឯកសារត្រឹមត្រូវតាមនីតិវិធីហើយ និងមានការឯកភាពពីលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី នោះភ្នាក់ងារមន្ទីរនឹងធ្វើការចុះបញ្ជីអចលនវត្ថុនោះ និងប្រថាប់ត្រាបញ្ជាក់នៅលើភ្ជាប់ជាមួយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះថាត្រូវជាប់បន្ទុកបញ្ចាំជាស្រេច។

**ឃ. ការកាន់កាប់សំណុំឯកសារ**

បន្ទាប់ពីកូនបំណុល និងតំណាងក្រុមហ៊ុនបានចុះកិច្ចសន្យាជាមួយគ្នាហើយនោះ កូន-បំណុលត្រូវប្រគល់ឯកសារមួយចំនួនទៅឲ្យក្រុមហ៊ុនជាអ្នកថែរក្សាឯកសារ មានដូចជាសៀវភៅគ្រួសារច្បាប់ដើម អត្តសញ្ញាណប័ណ្ណបុគ្គលដែលពាក់ព័ន្ធ វិញ្ញាបនបត្រដែលបានដាក់បញ្ចាំច្បាប់ដើម មកឲ្យក្រុមហ៊ុន ច្បាប់ដើម ។ ចំណែកឯកិច្ចសន្យាដទៃទៀតដូចមានរៀបរាប់ខាងលើត្រូវក្រុមហ៊ុនជាអ្នកកាន់កិច្ចសន្យាទាំងអស់១ ច្បាប់ និង ១ច្បាប់ទៀតកូនបំណុលជាអ្នកកាន់ ។

**ខ. ការដោះបំណុល**

នៅពេលដែលកូនបំណុលបានសងបំណុលមកក្រុមហ៊ុនគ្រប់ចំនួនហើយ នោះភ្នាក់ងារក្រុមហ៊ុននឹងចេញជាលិខិតដោះបំណុលដោយមានបញ្ជាក់ថាកូនបំណុលបានសងបំណុលគ្រប់

ចំនួនហើយ ហើយបន្ទាប់ពីចេញលិខិតនេះហើយ រាល់ការខូចខាតបាត់បង់ផ្សេងៗរបស់កូនបំណុល ពុំពាក់ព័ន្ធនឹងក្រុមហ៊ុនឡើយ ដោយធ្វើឡើងចំនួន ៣ច្បាប់( ១ច្បាប់តម្កល់នៅសាលាសង្កាត់ដែលទ្រព្យនោះតាំងនៅ ១ ច្បាប់ក្រុមហ៊ុនជាអ្នកកាន់ និង ១ច្បាប់ទៀតកូនបំណុលជាអ្នកកាន់។

លើសពីនេះក្រុមហ៊ុននឹងត្រូវធ្វើលិខិតស្នើសុំដើម្បីដោះបន្ទុក ទៅលោកប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដី និងត្រូវភ្ជាប់ជាមួយប័ណ្ណបញ្ជាក់កម្មសិទ្ធិដែលបានដាក់បន្ទុករួចហើយទៅផងដែរ។ នៅពេលដែលសំណុំឯកសារត្រូវបានបំពេញតាមនីតិវិធីហើយ និងមានការឯកភាពពីលោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីហើយ នោះភ្នាក់ងារមន្ទីរនឹងប្រថាប់ត្រាបន្ថែមទៀត បញ្ជាក់នៅលើភ្ជាប់ជាមួយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះថាត្រូវបានដោះបន្ទុកជាការស្រេច ហើយក្រុមហ៊ុនត្រូវប្រគល់ភ្ជាប់ជាមួយវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុនោះទៅឲ្យកូនបំណុលវិញដើម្បីប្រើប្រាស់ជាធម្មតា។

# ជំពូក ២

# ប្រាតិភោគដោយអនុប្បទាន

មុននឹងឈានដល់ការបកស្រាយអំពីប្រតិបត្តិប្រាតិភោគដោយអនុប្បទាន នៅក្នុងក្រុមហ៊ុនវីប្រេ្កាប្រចឹធី(២.២) យើងគប្បីត្រូវដឹងអំពីសញ្ញាណទូទៅនៃប្រាតិភោគដោយអនុប្បទានជាមុនសិន (២.១)។

## ២.១ សញ្ញាណទូទៅនៃប្រាតិភោគដោយអនុប្បទាន

តាមប្រវត្តិសាស្ត្រនៃនីតិឯកជនរបស់ប្រទេសកម្ពុជា ច្បាប់រដ្ឋប្បវេណីកន្លងមករួមទាំង ក្រមរដ្ឋប្បវេណីចាស់ ឆ្នាំ ១៩២០ ដោយចងក្រងឡើងវិញដោយលោក អេង សុត នៅឆ្នាំ ១៩៦៧ មិនមានចែងអំពី ប្រាតិភោគដោយអនុប្បទានទេ។ នៅក្នុងក្រមរដ្ឋប្បវេណីនេះឃើញ ថាមានតែបញ្ញត្តិអំពីការបញ្ចាំហើយ និងហ៊ីប៉ូតែកតែប៉ុណ្ណោះ។ ចំណែកឯបទប្បញ្ញត្តិច្បាប់ដទៃទៀត ក៏ដូចជាក្រឹត្យច្បាប់៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅពកិច្ចសន្យា ប្រកាសឲ្យប្រើ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៨៨ ក៏ពុំចែងអំពីប្រាតិភោគដោយអនុប្បទានដែរ។ រហូតមកដល់ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០៧ រដ្ឋសភាបានអនុម័តក្រមរដ្ឋប្បវេណីថ្មីមួយ នាសម័យប្រជុំលើកទី៧ នីតិកាលទី៣ ដោយប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧ និង

ចូលជាធរមានទៅតាមការកំណត់របស់ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឲ្យប្រើនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១។ ប្រាតិភោគដោយអនុប្បទានត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីថ្មី ឆ្នាំ ២០០៧នេះ នៅក្នុងជំពូកទី ៦ នៃគន្ថី ៦ ស្តីពី ការធានាកាតព្វកិច្ច។ ដើម្បីឲ្យកាន់តែយល់ច្បាស់ តទៅនឹងធ្វើការសិក្សាដោយបកស្រាយពីការកំណត់បង្ហាញ អំពីប្រាតិភោគដោយអនុប្បទាន (២.១.១) និងការបង្កើតប្រាតិភោគដោយអនុប្បទាន(២.១.២)។

### ២.១.១ កំណត់បង្ហាញនៃសិទ្ធិប្រាតិភោគដោយអនុប្បទាន

សិទ្ធិប្រាតិភោគដោយអនុប្បទានគឺជាប្រភេទមួយនៃសិទ្ធិប្រត្យក្ស[១៦] ដែលត្រូវចានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចាប់ពីមាត្រា ៨៨៨ រហូតដល់មាត្រា ៨៩៩។ ដូចដែលបានរៀបរាប់ក្នុងសេចក្តីផ្តើមខាងលើហើយថាសិទ្ធិប្រាតិភោគដោយអនុប្បទាន មិនធ្លាប់មានមកនោះទេនៅក្នុងប្រទេសកម្ពុជា។ វត្តមានសិទ្ធិប្រាតិភោគប្រត្យក្សនេះនៅក្នុងក្រមរដ្ឋប្បវេណីបច្ចុប្បន្ន គឺដោយសារមានការសហការពីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុន( JICA) ដែលនាំឲ្យមានច្បាប់នៃប្រទេសជប៉ុនជះឥទ្ធិពលមកលើក្រមរដ្ឋប្បវេណីរបស់កម្ពុជា។

ដើម្បីឲ្យកាន់តែការស្វែងយល់កាន់តែច្បាស់យើង នឹងសិក្សាទៅលើសញ្ញាណប្រាតិភោគដោយអនុប្បទាននៅក្នុងក្រមរដ្ឋប្បវេណី(២.១.១.១)។

#### ២.១.១.១ សញ្ញាណប្រាតិភោគដោយអនុប្បទាននៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

មុននឹងឈានដល់ការបកស្រាយអំពីប្រាតិភោគដោយអនុប្បទាន ជាបឋមពាក្យ អនុប្បទានជាពាក្យគន្លឹះដែលគួរឲ្យស្វែងយល់។ តាមសន្ទានុក្រមផ្នែករដ្ឋប្បវេណី ពាក្យ អនុប្បទាន មានន័យថាជាការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ដែលជាអនុប្បទាយី ទៅឲ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក[១៧]។ យោងតាមន័យនេះពាក្យប្រាតិភោគដោយអនុប្បទានមានន័យថា ជាការផ្ទេរសិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់កូនបំណុលទៅឲ្យម្ចាស់បំណុលដើម្បីធាននូវកាតព្វកិច្ចរបស់ខ្លួន។ កថាខណ្ឌទី១ មាត្រា ៨៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានឲ្យនិយមន័យ ប្រាតិភោគដោយអនុប្បទានថា ជាការណ៍ដែលកូនបំណុល ឬ តតិយជន ធ្វើអនុប្បទាននូវចលនវត្ថុរបស់ខ្លួនជា

---

[១៦] ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧, មាត្រា ៦៦៧។

[១៧] សន្ទានុក្រមរដ្ឋប្បវេណី, បោះពុម្ពដោយទីស្តីការគណៈមន្ត្រី,ឆ្នាំ ២០០៧ (តទៅហៅថា សន្ទានុក្រមផ្នែករដ្ឋប្បវេណី), ទំព័រ ២៧។

កំណត់ទៅឲ្យម្ចាស់បំណុលដើម្បីធានាកាតព្វកិច្ច។ ក្នុងករណីនេះ បើកាតព្វកិច្ចត្រូវបានសងរួច ហើយកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុត្រូវផ្ទេរទៅអ្នកបង្កើត។ ពាក្យ អនុប្បទាន ត្រូវបានប្រើក្នុងកថាខណ្ឌនេះដោយហេតុថាកម្មសិទ្ធិត្រូវបានផ្ទេរដើម្បីបង្កើតសិទ្ធិប្រត្យក្ស ហើយចែងផងដែរថា កម្មសិទ្ធិត្រូវផ្ទេរទៅកូនបំណុលដោយការសងកាតកិច្ច[១៨]។ ពាក្យអនុប្បទាននៅក្នុងករណីនេះមិនសម្តៅលើការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុឡើយ ប៉ុន្តែគឺជាការផ្ទេរកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនោះទៅឲ្យម្ចាស់បំណុល (ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន) ជាបណ្តោះអាសន្នរហូតដល់ពេលកាតព្វកិច្ចត្រូវបានសង។

ទស្សនៈនេះត្រូវបានលើកឡើងដោយពិចារណាទៅលើវាក្យខណ្ឌទី២ កថាខណ្ឌទី១ នៃមាត្រាខាងលើដែលបានចែងថាក្នុងករណីនេះ បើកាតព្វកិច្ចត្រូវបានសងរួចហើយ កម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុត្រូវផ្ទេរទៅអ្នកបង្កើត។ ដូចនេះអ្នកបង្កើត (អាចជាកូនបំណុល ឬតតិយជន) អាចដាក់ទ្រព្យរបស់ខ្លួនដោយផ្ទេរកម្មសិទ្ធិលើទ្រព្យនោះទៅឲ្យម្ចាស់សិទ្ធិមួយរយៈ ដើម្បីធានានូវបំណុលដែលបានខ្ចី ហើយនៅពេលដែលអ្នកបង្កើតបានសងកាតព្វកិច្ចនោះហើយ ម្ចាស់សិទ្ធិត្រូវផ្ទេរកម្មសិទ្ធិលើទ្រព្យនោះទៅឲ្យអ្នកបង្កើតវិញ។ ប៉ុន្តែមិនមានន័យថា បដិសេធមិនឲ្យប្រគល់វត្ថុក្នុងការបង្កើតប្រាតិភោគដោយអនុប្បទាននោះទេ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានបើកសិទ្ធិសេរីភាពឲ្យភាគីធ្វើការព្រមព្រៀង។ ឧទាហរណ៍ លោក ក ចង់ខ្ចីប្រាក់ លោក ខក្នុងតម្រូវការមួយចាំបាច់។ ប៉ុន្តែដោយផ្តោតលើបញ្ហាផ្នែកទំនុកចិត្ត លោក ខ បានតម្រូវឲ្យលោក ក ដាក់ទ្រព្យ ដើម្បីធានាកាតព្វកិច្ច។ លោក កបានសម្រេចចិត្តដាក់ទ្រព្យរបស់ខ្លួនសម្រាប់ធនាកាតព្វកិច្ចចំពោះលោក ខ ដោយធ្វើអនុប្បទានចលវត្ថុនោះទៅឲ្យលោក ខ។ ក្នុងកិច្ចព្រមព្រៀងនេះលោក ក និងសម្មតិកម្មនេះគឺការបង្កើតឡើងនូវប្រតិបត្តិឡើងនៃការធានាសិទ្ធិលើបំណុលមួយប្រភេទដោយចលនវត្ថុដែលមិនតម្រូវឲ្យមានការប្រគល់វត្ថុជាចាំបាច់ ហើយប្រតិបត្តិការប្រភេទនេះត្រូវបានច្បាប់កំណត់ថាជា ប្រាតិភោគដោយអនុប្បទាន។

## ២.១.២ ការបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន

ក្នុងទំនាក់ទំនងនៃរឿងរដ្ឋប្បវេណីរបស់បុគ្គលឯកជន ទាមទារសំខាន់បំផុត គឺគោលការណ៍ស្វ័យភាពឆន្ទៈរបស់ភាគីក្នុងការធ្វើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី ដែលជាគោលការណ៍ដ៏

[១៨] ក្រសួងយុត្តធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០១០, ភាគទី៤ គន្ថីទី៦,ទំព័រ១០២។

ចម្បងមួយនៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧[១៩]។ ដូចគ្នាដែរ កិច្ចសន្យាប្រាតិភោគដោយអនុប្បទានក៏ត្រូវគោរពនូវគោលការណ៍នេះ។ លើសពីនេះទៅទៀត កិច្ចសន្យានេះក៏មិនខុសពីកិច្ចសន្យាផ្សេងទៀតឡើយ ដែលតម្រូវឲ្យភាគីត្រូវតែគោរពនូវល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់មួយចំនួន ដូចជាលក្ខខណ្ឌគ្រឹះ (២.១.២.១) ល័ក្ខខ័ណ្ឌលក្ខខណ្ឌទម្រង់ (២.១.២.២) និងលក្ខខណ្ឌតតាំង(២.១.២.៣) ដើម្បីឲ្យកិច្ចសន្យាមានសុពលភាពស្របតាមច្បាប់ និងមានអានុភាពចំពោះតតិយជន។

**២.១.២.១ លក្ខខណ្ឌគ្រឹះ**

ដើម្បីឲ្យកិច្ចសន្យាប្រាតិភោគដោយអានុប្បទានមួយមានសុពលភាព ល័ក្ខខ័ណ្ឌគ្រឹះជាលក្ខខណ្ឌដ៏សំខាន់ដែលមិនអាចខ្វះបាន ដែលតម្រូវឲ្យកិច្ចសន្យានោះកើតចេញពីសេរីភាពនៃការព្រមព្រៀង (ចំណុច ក) សមត្ថភាព(ចំណុច ខ) និងកម្មវត្ថុ(ចំណុច គ) ដែលស្របច្បាប់ ឬមិនផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈនិងទំនៀមទម្លាប់ដ៏ល្អរបស់កម្ពុជា។

**ក. ការព្រមព្រៀង**

កិច្ចសន្យាប្រាតិភោគដោយអនុប្បទាន ត្រូវតែបង្កើតឡើងពីឆន្ទៈដោយសេរី និងពិតប្រាកដរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទាន និងអ្នកបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទាន។ បើពុំនោះទេនាំឲ្យមាននូវវិការៈមួយចំនួនកើតឡើង ដែលជាហេតុនាំឲ្យភាគីអាចលុបចោលកិច្ចសន្យានោះបាន។ វិការៈនៃការព្រមព្រៀងនេះដែរ ត្រូវបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដូចជាការភាន់ច្រឡំ ការឆបោក ការផ្តល់ពត៌មានមិនពិត ការគម្រាមកំហែង ការកេងចំណេញហួសហេតុ ការរំលោភបំពានលើស្ថានភាព។ ប៉ុន្តែរាល់វិការៈខាងលើនេះមិនមែនសុទ្ធតែអាចអះអាងនៅក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទានបានទាំងស្រុងទេ។ ឧទាហរណ៍ នៅពេលដែលកូនបំណុលយកទ្រព្យរបស់ខ្លួន ដែលជាចលនវត្ថុប្រគល់ទៅឲ្យម្ចាស់បំណុលដើម្បី ធានាកាតព្វកិច្ចចំពោះកិច្ចសន្យាខ្ចីបរិភោគ ជាទូទៅ វត្ថុដែលដាក់ធានាតែងតែមានតម្លៃថ្លៃជាងចំនួនទឹកប្រាក់ដែលឲ្យខ្ចី ប៉ុន្តែកូនបំណុលមិនអាចលុបចោលកិច្ចសន្យា ដោយអះអាងថាជាការចំណេញហួសហេតុបានទេ។ ទោះបីជាវត្ថុមានតម្លៃថ្លៃជាងបំណុលក៏ដោយ ការប្រគល់វត្ថុគឺដើម្បីធានាបំណុលតែប៉ុណ្ណោះកូនបំណុល នឹងទទួលបានទ្រព្យនោះមកវិញនៅពេលដែលខ្លួនសងបំណុល ហើយទោះបីជាកូនបំណុលគ្មានលទ្ធភាពក្នុងការសងបំណុលក៏ដោយ ក៏ច្បាប់កំណត់ឲ្យម្ចាស់បំណុលទទួលបានការ

[១៩] មាត្រា ៣ នៃក្រមរដ្ឋប្បវេណី

សងត្រឹមតែទំហំដែលមានលើបំណុលនោះប៉ុណ្ណោះ ពោលគឺម្ចាស់បំណុលមិនអាចយកវត្ថុនោះផ្តាច់តែម្តងឡើយ។ ករណីនេះ ពុំអាចលើកឡើងថាជាកិច្ចសន្យាលក់ទិញដែលវត្ថុមានតម្លៃថ្លៃលើសលប់លើទឹកប្រាក់ដែលត្រូវបង់នោះទេ។ ចំណែកឯការគម្រាមកំហែង ក៏កម្រនឹងកើតមានដែរនៅក្នុងកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន។

ទោះជាយ៉ាងណាក៏ដោយ ក៏កិច្ចសន្យាដែលបានបង្កើតដោយភ្ជាប់ជាមួយវិការៈនៃការព្រមព្រៀង នៅតែមានសុពលភាពរហូតដល់ពេលដែលអ្នកមានសិទ្ធិលុបចោល ធ្វើការលុបចោលកិច្ចសន្យា[២០]។ ច្បាប់បានអនុញ្ញាតឲ្យលុបចោលកិច្ចសន្យានេះបានក្នុងរយៈពេល ៣ឆ្នាំ បន្ទាប់ពីអ្នកមានសិទ្ធិលុបចោលបានដឹងអំពីវិការៈនៃការព្រមព្រៀង ឬក្នុងរយៈពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃការបង្កើតកិច្ចសន្យា។ ប្រសិនបើ អ្នកដែលមានសិទ្ធិលុបចោលមិនលុបចោលក្នុងរយៈពេលខាងលើនេះទេ នោះសិទ្ធិលុបចោលនឹងត្រូវរលត់[២១]។ ផ្ទុយទៅវិញប្រសិនបើកិច្ចសន្យាត្រូវបានលុបចោលនោះសិទ្ធិ និងកាតព្វកិច្ចក៏ត្រូវរលត់។ ដូចនេះដើម្បីទាមទារឲ្យសងបំណុល ឬវត្ថុមកវិញអ្នកមានសិទ្ធិលុបចោល ត្រូវទាមទារដោយផ្អែកលើសេចក្តីចម្រើនដោយឥតហេតុ ព្រោះរាល់ការទាមទារត្រូវតែមានមូលហេតុត្រឹមត្រូវតាមផ្លូវច្បាប់។

សរុបសេចក្តីមក ទោះជាការបង្ហាញឆន្ទៈមានវិការៈក៏ដោយ ក៏កិច្ចសន្យាប្រាតិភោគដោយអនុប្បទានមានសុពលភាពដែរ តែច្បាប់ទុកលទ្ធភាពឲ្យអ្នកដែលបង្ហាញឆន្ទៈមានវិការៈ ឬអ្នកដែលមានសិទ្ធិលុបចោលអាចលុបចោលកិច្ចសន្យាបាន។ ប៉ុន្តែប្រសិនបើបុគ្គលទាំងនោះមិនបានលុបចោល កិច្ចសន្យាតាមអាជ្ញាយុកាលដែលបានកំណត់ទេ កិច្ចសន្យានោះនឹងមានអានុភាពអនុវត្តហើយភាគីត្រូវតែគោរពតាម។

### ខ. សមត្ថភាព

មុននឹងឈានដល់ការបកស្រាយ ជាបឋមយើងគួរស្វែងយល់ពីពាក្យ សមត្ថភាព ជាមុនសិន។ ពាក្យថា សមត្ថភាព នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មានន័យថាជាលក្ខណៈសម្បត្តិរបស់បុគ្គលដែលតម្រូវដោយច្បាប់[២២]។ ក្នុងការបង្កើតកិច្ចសន្យាផ្សេងៗក៏ដូចជាកិច្ចសន្យាប្រាតិភោគ

[២០] មាត្រា៣៥៨ កថាខ័ណ្ឌទី១ ក្រមរដ្ឋប្បវេណី ២០០៧។

[២១] មាត្រា ៣៦៣ កថាខ័ណ្ឌទី១,២ ក្រមរដ្ឋប្បវេណី ២០០៧។

[២២] សទ្ទានុក្រមរដ្ឋប្បវេណី ទំព័រ ២

ដោយអនុប្បទានឲ្យមានសុពលភាព ភាគីនៃកិច្ចសន្យាត្រូវតែជាសមត្ថជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមការកំណត់របស់ច្បាប់ ពោលគឺជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាព[២៣]។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបញ្ញត្តិនូវជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពមានដូចជា អនីតិជន ជនក្រោមអាណាព្យាបាលទូទៅ និងជនក្រោមហិតូបត្ថម្ភ[២៤]។ ការកំណត់បែបនេះដោយសារតែបុគ្គលទាំងនោះខ្វះសមត្ថភាពខាងឆន្ទៈ ពោលគឺមិនអាចត្រិះរិះពិចារណាអំពីលទ្ធផលដែលកើតចេញពីអំពើរបស់ពួកគេបានឡើយ ។ ជនដែលត្រូវបានកម្រិតសមត្ថភាពអាចធ្វើសកម្មភាពមួយចំនួន ដែលពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃដោយឯករាជ្យ ប៉ុន្តែចំពោះសកម្មភាពមួយចំនួនទៀត ដូចជាកិច្ចសន្យាប្រាតិភោគដោយអនុប្បទានច្បាប់កំណត់ឲ្យត្រូវមានការយល់ព្រមពីអ្នកតំណាងដែលច្បាប់កំណត់ ឬហិតូបត្ថម្ភកៈទេ កិច្ចសន្យាប្រាតិភោគដោយអនុប្បទានដែលបង្កើតឡើងដោយជនទាំង ៣ប្រភេទនោះអាចនឹងត្រូវបានលុបចោល។ ប៉ុន្តែច្បាប់បានធ្វើការលើកលែងចំពោះអនីតិជនដែលមានអត្តាធីនភាព ព្រោះការទទួលបានអត្តាធីនភាពត្រូវចាត់ទុកថាអនីតិជននោះបានដល់នីតិភាព ។ ដោយសារកិច្ចសន្យានឹងមានសុពលភាពរហូតដល់អ្នកដែលមានសិទ្ធិលុបចោលធ្វើការលុបកិច្ចសន្យា ដូចនេះជនដែលត្រូវបានកម្រិតសមត្ថភាពក៏អាចធ្វើកិច្ចសន្យាប្រាតិភោគដោយអនុប្បទានឲ្យមានសុពលភាពបានដែរ ដរាបណាគ្មានការលុបចោល។ អ្នកដែលមានសិទ្ធិលុបចោលកិច្ចសន្យាអាចជាសាមីខ្លួន អ្នកតំណាងដោយច្បាប់កំណត់ ឬហិតូបត្ថម្ភកៈ នៃជននោះ។ លើសពីនេះសន្តតិជន ឬអច្ច័យលាភីសកលរបស់ខ្លួនក៏អាចលុបចោលកិច្ចសន្យានេះបានដែរ[២៥]។

**គ. កម្មវត្ថុ**

ក្រៅពីការព្រមព្រៀង និងសមត្ថភាពក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានលក្ខខណ្ឌមួយទៀតដែលសំខាន់ផងដែរនោះគឺ ទាក់ទងទៅនឹងវត្ថុដែលជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទាន។ កម្មវត្ថុនៃសិទ្ធិប្រាតិភោគដោយអនុប្បទានគឺ ចលនវត្ថុ។ ទាំងបណ្តាច្បាប់ចាស់និងច្បាប់ដែលចូលជាធរមាន ពាក្យ ចលនវត្ថុ មិនត្រូវបានឲ្យនិយមន័យច្បាស់លាស់ទេ។ ក្រមរដ្ឋ-

[២៣] ពាក្យ សកម្មភាព នៅក្នុងក្រមរដ្ឋវេណីត្រូវបានឲ្យនិយមន័យថាជាឆន្ទៈតាមកិច្ចសន្យា ឬសកម្មភាពឯកតោភាគីដែលបង្កើតបានជាសិទ្ធិ និងកាតព្វកិច្ច។

[២៤] មាត្រា ១៦ ក្រមរដ្ឋប្បវេណី ២០០៧។

[២៥] មាត្រា ៣៥៩ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី ២០០៧

ប្បវេណីឆ្នាំ ២០០៧ គ្រាន់តែកំណត់ថាចលនវត្ថុសំដៅលើវត្ថុក្រៅពីអចលវត្ថុ[២៦]។ ដូច្នេះតាមន័យនេះ រាល់វត្ថុក្រៅពីដីធ្លី សំណង់អាគារ ដំណាំ រុក្ខជាតិផ្សេងៗដែលជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបានគឺជា ចលនវត្ថុ។ ប៉ុន្តែមានច្បាប់ពិសេសមួយគឺ ច្បាប់ស្តីពីប្រត្តិបត្តិការដែលមានកិច្ចធានា ដែលប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៧ បានកំណត់អំពីប្រតិបត្តិការខ្ចីប្រាក់ទាំងឡាយណា ដែលដាក់ចលនទ្រព្យជាទ្រព្យធានានៅក្នុងវិស័យពាណិជ្ជកម្ម ដោយគ្របដណ្តប់ទាំងប្រាតិភោគដោយអនុប្បទានផងដែរ។ ច្បាប់នេះបានធ្វើការបែងចែកអំពីទ្រព្យធានានៃចលនវត្ថុគ្រប់ប្រភេទ[២៧]។ ទំនិញទាំងនោះរួមមានទំនិញសារពើភ័ណ្ឌ កសិផល ឧបករណ៍ ទំនិញប្រើប្រាស់ និងចលនវត្ថុតាំងភ្ជាប់ជាដើម។ តើទំនិញទាំងអស់នេះសម្តៅទៅលើអ្វីខ្លះ? ដូច្នេះដើម្បីជាការងាយស្រួលក្នុងការស្វែងយល់ តទៅនឹងធ្វើការបកស្រាយជាបន្តបន្ទាប់នៅខាងក្រោមនេះ។

ទំនិញសារពើភណ្ឌ ជាទំនិញទុកសម្រាប់លក់ ឬជួល ឬទំនិញជាវត្ថុធាតុដើម មានដូចជា ម៉ាស៊ីនដេរ ដែលកំពុងដំណើរការក្នុងរោងចក្រ ឬម៉ាស៊ីនកុំព្យូទ័រដែលដាក់លក់ក្នុងហាង។ ចំណែកកសិផលជាទំនិញរបស់កូនបំណុលដែឡទាក់ទង និងកសិដ្ឋានមានដូចជា សត្វចិញ្ចឹមពាហនៈ ដំណាំដាំដុះ និងផលដែលទទួលបានទំនិញដែលប្រើប្រាស់ជាចម្បងសម្រាប់គោលបំណងផ្ទាល់ខ្លួនសមាជិកគ្រួសារដែលមានជាលក្ខណៈបុគ្គល ឬគ្រួសារដែលមានដូចជា កុំព្យូទ័រ ទូរទស្សន៍។ រីឯឧបករណ៍គឺជាទំនិញដែលមិនមែនជាកសិផលទេ គឺជាសារពើភណ្ឌ ឬទំនិញប្រើប្រាស់ ដូចជា ឡរបស់ហាងនំប៉័ង និងនំផ្សេងៗរបស់ហាងនំមួយ ម៉ាស៊ីនថតចម្លង ដែលប្រើប្រាស់ក្នុងការិយាល័យមួយ។ ចុងក្រោយនោះគឺ វត្ថុតាំងភ្ជាប់ ជាទំនិញដែលត្រូវបានភ្ជាប់ទៅនឹងអចលវត្ថុមានគោលបំណងភ្ជាប់ទៅនឹងអចលវត្ថុតាមរបៀបណាមួយ ដែលនាំឲ្យមានសិទ្ធិភណ្ឌិកកើតឡើងតាមច្បាប់ភូមិបាលឆ្នាំ ២០០១។ ឧទាហរណ៍ៈ ម៉ាស៊ីនត្រជាក់ដែលនៅជាប់អាគារ។

ដូច្នេះ ដោយយោងតាមច្បាប់ស្តីពីប្រតិបត្តិការ ដែលមានកិច្ចធានាដែលជាច្បាប់ពិសេសបំពេញបន្ថែមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ វត្ថុដែឡអាចជាកម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានគឺជាចលនទ្រព្យ និងទំនិញផ្សេងៗ ដោយរាប់បញ្ចូលទាំងអចលវត្ថុតាមភ័ព្វព្រេងវាសនា ក៏អាចដាក់ប្រាតិភោគបានដែរ។ កថាខណ្ឌទី២ មាត្រា ៨៨៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងថា

[២៦] មាត្រា ១២០ កថាខណ្ឌទី ៣ ក្រមរដ្ឋប្បវេណី ២០០៧

[២៧] មាត្រា ៦ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា,ប្រកាសឲ្យប្រើថ្ងៃទី ២៤ ឧសភា ឆ្នាំ ២០០៧ (តទៅហៅថា ច្បាប់ស្តីពីប្រតិបត្តិដែលមានកិច្ចធានាឆ្នាំ ២០០៧)

ចលនវត្ថុច្រើនដែលត្រូវបានកំណត់ទំហំតាមមាត្រដ្ឋានដូចជាប្រភេទ ឬកន្លែងស្ថិតនៅនៃចលនវត្ថុ អាចយកមកធ្វើជាកម្មវត្ថុនៃ សិទ្ធិប្រាតិភោគដោយអនុប្បទាន ដោយចាត់ទុកចលនវត្ថុផ្តុំគ្នាតែមួយបាន ទោះបីជាចលនវត្ថុផ្តុំគ្នានោះមានការប្រែប្រួលដ៏ដោយ ខ្លឹមសារកថាខណ្ឌនេះមានន័យថា កម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានអាចជា ចលនវត្ថុច្រើនដែលមានប្រភេទដូចគ្នា ឬស្ថិតនៅកន្លែងតែមួយ ពោលគឺសម្តៅលើចលនវត្ថុ និងទំនិញដែលបានរៀបរាប់ខាងលើនេះ។ ឧទាហរណ៍ លោក ក ជាអ្នកលក់ដុំ គាត់មានបំណងចង់ខ្ចីប្រាក់លោក ខ ដើម្បីពង្រីកមុខជំនួញរបស់គាត់។ ជំនួសឲ្យការខ្ចីប្រាក់លោក ខ ទាមទារឲ្យលោក ក ដាក់ប្រាតិភោគ។ លោក ក គ្មានអចលនវត្ថុទេ គាត់មានតែទំនិញនៅក្នុងឃ្លាំង (ទំនិញសារពើភណ្ឌ) ដែលត្រូវលក់ទៅឲ្យអ្នកលក់រាយ ហើយទំនិញនីមួយៗនឹងត្រូវផ្លាស់ប្តូរជារៀងរាល់ថ្ងៃ។ ដូចនេះ គាត់មិនអាចយកទំនិញនោះដាក់បញ្ចាំនោះបានទេ។ ករណីនេះដើម្បីខ្ចីប្រាក់បានលោក ក អាចបង្កើតកិច្ចសន្យាប្រាតិភោឡដោយអនុប្បទានជាមួយលោក ខ បានដោយអនុប្បទាននូវកម្មសិទ្ធិលើចលនវត្ថុទាំងអស់នោះទៅឲ្យលោក ខ រហូតដល់ពេលដែលលោក ក សងបំណុលវិញ ទើបផ្ទេរកម្មសិទ្ធិលើវត្ថុទាំងនោះមកលោក ក វិញ។ បន្ទាប់ពីពីបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានហើយ លោក ក (អ្នកបង្កើត) នៅតែអាចបន្តកាន់កាប់ដោយចំពោះនូវវត្ថុដែលជាកម្មវត្ថុបានដោយផ្ទាល់ ដូច្នេះគាត់អាចបន្តការជួញដូរទំនិញរបស់គាត់បានដោយរលូន។

ប្រាតិភោគដោយអនុប្បទានចំពោះចលនវត្ថុផ្តុំគ្នា មានសារៈប្រយោជន៍ដល់កូនបំណុលដូចជា ពាណិជ្ជករ ឬអាជីវករ ឬកសិករ ជាដើម ព្រោះគាត់អាចយកទំនិញទាំងអស់ដែលគាត់មានទៅដាក់ប្រាតិភោគបាន ជំនួសឲ្យការដែលយកអចលនវត្ថុដូចជា ដីធ្លីរបស់គាត់ទៅដាក់បញ្ចាំ ឬហ៊ីប៉ូតែក ហើយទទួលបាននូវប្រាក់កម្ចីច្រើនគួរសមដែរ។ លើសពីនេះ ទោះបីជាវត្ថុត្រូវបានបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានរួចហើយក៏ដោយ កូនបំណុល នៅតែអាចទទួលបានផលប្រយោជន៍ពីវត្ថុតាមរយៈការកាន់កាប់ដោយផ្ទាល់ ដូចនេះប្រតិបត្តិការនេះអាចឲ្យកូនបំណុលមានលទ្ធភាពក្នុងការសងបំណុលបានឆាប់រហ័សបើប្រៀបធៀបទៅនឹងការបញ្ចាំចលនវត្ថុ។

ទោះជាយ៉ាងណាក៏ដោយ កម្មវត្ថុនៃប្រាតិភោគដោយអនុប្បទានត្រូវតែជាវត្ថុដែលមានតម្លៃសេដ្ឋកិច្ចអាចធ្វើអនុប្បទានបាន។ សិទ្ធិប្រាតិភោគប្រត្យក្ស[២៨] មិនអាចយកវត្ថុ ឬសិទ្ធិណាដែលមិន

[២៨] សិទ្ធិប្រាតិភោគប្រត្យក្សក្នុងក្រមរដ្ឋប្បវេណី មាន ប្រាំប្រភេទ គឺ សិទ្ធិឃាត់ទុក ឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ ហ៊ីប៉ូតែក និងសិទ្ធិប្រាតិភោគដោយអនុប្បទាន។

អាចធ្វើអនុប្បទានបានមកធ្វើជាកម្មវត្ថុបានទេ[២៩] ព្រោះនៅពេលវត្ថុមួយត្រូវបានដាក់ប្រាតិភោគដោយអនុប្បទាន គោលបំណងគឺដើម្បីធានាកាតព្វកិច្ចរបស់អ្នកបង្កើតចំពោះម្ចាស់សិទ្ធិ។ ប្រសិនបើនៅពេលដល់កំណត់សងអ្នកបង្កើតមិនអាចអនុវត្តកាតព្វកិច្ចសងបានទេនោះ វត្ថុនោះនឹងត្រូវបានធ្វើការចាត់ចែងជាប្រាក់ដើម្បីទូទាត់បំណុល។ ដូចនេះ វត្ថុដែលមិនអាចប្តូរជាប្រាក់ដោយសារការមិនអាចធ្វើអនុប្បទាន មិនអាចក្លាយជាកម្មវត្ថុនៃកិច្ចសន្យាប្រាតិភោគដោយអនុប្បទានបានឡើយ។ មិនតែប៉ុណ្ណោះ កម្មវត្ថុត្រូវតែជាវត្ថុដែលស្របច្បាប់ ឬមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អរបស់ព្រះរាជាណាចក្រកម្ពុជា បើមិនដូច្នោះទេ កិច្ចសន្យាត្រូវទុកជាមោឃៈ ពោលគឺ គ្មានអានុភាពឡើយ។

### ២.១.២.២ លក្ខខណ្ឌទម្រង់

ក្រៅពីល័ក្ខខ័ណ្ឌគ្រឹះដែលបានរៀបរាប់ខាងលើ ល័ក្ខខ័ណ្ឌទម្រង់ ក៏ជាធាតុផ្សំដ៏សំខាន់មួយក្នុងការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានឲ្យមានអានុភាពអនុវត្តចំពោះភាគី។

សិទ្ធិប្រាតិភោគដោយអនុប្បទានត្រូវបានបង្កើតឡើង ដោយការព្រមព្រៀងរវាងម្ចាស់បំណុល និងកូនបំណុល ឬតតិយជនដែលផ្តល់ចលនវត្ថុសម្រាប់ប្រាតិភោគដោយអនុប្បទាន[៣០]។ កិច្ចសន្យាប្រាតិភោគដោយអនុប្បទានត្រូវបង្កើតឡើងដោយឈរលើគោលការនៃការព្រមព្រៀងរបស់គូភាគី។ ក្នុងការបង្កើតកិច្ចសន្យានេះឲ្យមានអានុភាព គឺគ្រាន់តែតម្រូវឲ្យមានការព្រមព្រៀងពីគូភាគីតែប៉ុណ្ណោះ។ ដូច្នេះ ការព្រមព្រៀងគឺជាល័ក្ខខ័ណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទាន។ ការប្រគល់វត្ថុ មិនមែនជាល័ក្ខខ័ណ្ឌក្នុងការបង្កើតប្រាតិភោគដោយអនុប្បទានបានឡើយ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានទុកលទ្ធភាពឲ្យភាគីធ្វើការព្រមព្រៀងដោយសេរី។

ទោះជាយ៉ាងណាក៏ដោយ នេះគឺជាបទប្បញ្ញត្តិនៃច្បាប់តែប៉ុណ្ណោះ ចំណែកឯការអនុវត្តជាក់ស្តែងនៅមានលក្ខណៈខុសគ្នាច្រើន។ សព្វថ្ងៃនេះ យើងឃើញថាការប្រកបអាជីវកម្មប្រាតិភោគដោយអនុប្បទានអាជីវករដែលជាម្ចាស់ប្រាតិភោគដោយអនុប្បទានតែងតែ ទទួលបាននូវការប្រគល់ នៅពេលដែលអាជីវករនោះផ្តល់ប្រាក់កម្ចីទៅឲ្យអតិថិជនដែលជាអ្នកបង្កើត(ភាគច្រើនអាជីវ-កម្មនោះ អនុវត្តប្រាតិភោគដោយអនុប្បទានចំពោះចលនវត្ថុធម្មតាដូចជា ការបញ្ចាំចលនវត្ថុ)។

[២៩] មាត្រា ៧៦៨ វាក្យខណ្ឌទី១ ក្រមរដ្ឋប្បវេណី ២០០៧

[៣០] មាត្រា ៨៨៩ ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។

ករណីដែលបង្កើតកិច្ចសន្យាដោយអនុប្បទានដោយគ្រាន់តែព្រមព្រៀង និងដោយមិនប្រគល់វត្ថុគឺកម្រកើតមានណាស់ប្រជាពលរដ្ឋនៅតែបន្តធ្វើតាមទម្លាប់នៃការបញ្ចាំចលនវត្ថុដែលបានចាក់ឫសគល់នៅក្នុងប្រទេសយើងតាំងពីយូរណាស់មកហើយ។ លើសពីនេះលិខិតបទដ្ឋានគតិយុត្តមួយចំនួនដែលគ្របដណ្តប់ទៅលើអាជីវកម្មទាំងនេះមានដូចជា ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២៨ សហវ.ប្រក ស្តីពីការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញលក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាក់តិភោគដោយអនុប្បទាន ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១០ មិនបានកំណត់អំពីកាតព្វកិច្ចរបស់ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានដាច់ដោយឡែកពីម្ចាស់សិទ្ធិលើការបញ្ចាំឡើយ។ ប្រកាសនេះបានតម្រូវអាជីវករត្រូវរក្សាទ្រព្យធានាឲ្យមានសុវត្ថិភាព ដោយមិនបានលើកឡើងពីករណីដែលបង្កើតប្រាតិភោគដោយអនុប្បទានដោយគ្មានការប្រគល់វត្ថុឡើយ។

យ៉ាងណាមិញ គោលបំណងនៃក្រមរដ្ឋប្បវេណីដឡែកំណត់អំពីការបង្កើតកិច្ចសន្យាប្រាតិ-ភោគដោយអនុប្បទានដោយការព្រមព្រៀង គឺសម្តៅលើកិច្ចសន្យាដែលបង្កើតចំពោះចលនវត្ថុច្រើនផ្តុំគ្នាដែលបានរៀបរាប់ខាងលើ (កម្មវត្ថុ) ព្រោះវាជាការលំបាកក្នុងការប្រគល់វត្ថុទាំងអស់នោះហើយក៏មិនអាចធ្វើទៅបានឡើយចំពោះករណីមួយចំនួនដូចជា វត្ថុទាំងនោះជាទំនិញសារពើភ័ណ្ឌនៃអាជីវកម្មរបស់អ្នកបង្កើត ដែលត្រូវលក់ដូរដូចខាងលើ។ ហេតុនេះហើយ ទើបក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ អនុញ្ញាតឲ្យភាគីអាចបង្កើតសិទ្ធិប្រាតិភោគដោយអនុប្បទានបានដោយការព្រមព្រៀងគឺជាការគ្រប់គ្រាន់។ ប្រតិបត្តិការនេះភាគច្រើនត្រូវបានគេអនុវត្តនៅក្នុងវិស័យពាណិជ្ជកម្មដែលមានទ្រង់ទ្រាយធំ និងពាក់ព័ន្ធដោយផ្ទាល់ដល់ការជួញដូររបស់ពាណិជ្ជករ។

### ២.១.២.៣ លក្ខខណ្ឌតតាំង

ម្យ៉ាងទៀតដើម្បីឲ្យកិច្ចសន្យាប្រាតិភោគដោយអនុប្បទាននេះមានអានុភាពអាចតតាំងនឹងតតិយជនបាន ភាគីគប្បីត្រូវគោរពតាមល័ក្ខខ័ណ្ឌតតាំង ដែលត្រូវបានកំណត់ដោយច្បាប់។ ដោយយោងតាមមាត្រា ៨៩០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានមិនអាចតតាំងសិទ្ធិប្រាតិភោគដោយអនុប្បទានបានឡើយ បើមិនបានទទួលការផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុដោយយោងតាមបញ្ញត្តិនៃមាត្រា ២២៩ (ការផ្ទេរការកាន់កាប់)នៃក្រមរដ្ឋប្បវេណីនេះទេ។ ដូចនេះដើម្បីតតាំងប្រាតិភោគដោយអនុប្បទានដែលបានបង្កើតដោយការព្រមព្រៀងរវាងភាគីចំពោះតតិយជន ចាំបាច់ត្រូវផ្ទេរការកាន់កាប់នៃវត្ថុដែលជាកម្មវត្ថុ។ ការផ្ទេរការកាន់កាប់នៅទីនេះត្រូវបានរួមបញ្ចូលទាំង ៤ទម្រង់នៃការផ្ទេរការកាន់កាប់ដែលបញ្ញត្តិក្នុងមាត្រា ២២៩ នៃក្រម

ដដែល។ ការផ្ទេរការកាន់កាប់ទាំងអស់នោះមានដូចជា ការប្រគល់ដោយជាក់ស្តែងការប្រគល់ដោយសង្ខេប កាប្រគល់ដោយបញ្ញា និងការប្តូរលក្ខណៈនៃការកាន់កាប់។

ដូច្នេះ តើទម្រង់នៃការផ្ទេរការកាន់កាប់ទាំងអស់នោះ ប្រព្រឹត្តិទៅយ៉ាងដូចម្តេចនៅក្នុងប្រាតិភោគដោយអនុប្បទាន?

ទម្រង់ទី១ ៖ ការប្រគល់ដោយជាក់ស្តែង គឺសម្តៅលើការណ៍ដែលការកាន់កាប់ត្រូវបានផ្ទេរដោយការប្រគល់វត្ថុកាន់កាប់ មានន័យថាអនុប្បទានយីធ្វើការផ្ទេរការកាន់កាប់ដោយប្រគល់វត្ថុទៅអនុប្បទានិកកាន់កាប់។

ទម្រង់ទី២ ៖ ការប្រគល់ដោយសង្ខេប ជាការផ្ទេរដោយមានការព្រមព្រៀងគ្នារវាងភាគីតែប៉ុណ្ណោះ។ ក្នុងករណីនេះនៅពេលដែលអ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ (អនុប្បទានិក) ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះតាមការជាក់ស្តែង នោះវត្ថុនោះនឹងត្រូវផ្ទេរទៅបុគ្គលនោះដោយការព្រមព្រៀងប៉ុណ្ណោះ។ ដោយសហេតុនេះ អនុប្បទាយីនៃការកាន់កាប់ ត្រូវបាត់បង់នូវការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់ តាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់។

ទម្រង់ទី៣ ៖ ការផ្ទេរការកាន់កាប់ដោយបញ្ញា ជាការផ្ទេររវាងអ្នកកាន់កាប់ដោយប្រយោលតាមរយៈអ្នកដទៃ ជាមួយនិងតតិយជន។ អ្នកកាន់កាប់ដោយប្រយោលតាមរយៈអ្នកដទៃអាចផ្ទេរការកាន់កាប់ទៅឲ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយតតិយជន និងដោយការជូនដំណឹងអំពីហេតុនោះទៅឲ្យអ្នកកាន់កាប់ដោយចំពោះ។

ទម្រង់ទី៤ ៖ ការប្តូរលក្ខណៈនៃការកាន់កាប់ ជាការផ្ទេរដោយគ្រាន់តែមានការព្រមព្រៀងគ្នារវាងភាគីតែប៉ុណ្ណោះដោយគ្មានការប្រគល់ដោយជាក់ស្តែងទេ អាចនិយាយបានថាវត្ថុមិនទាន់ត្រូវបានប្រគល់ ប៉ុន្តែសិទ្ធិត្រូវបានផ្ទេរ។ ករណីនេះ អនុប្បទានិកនៃការកាន់កាប់ត្រូវទទួលការផ្ទេរការកាន់កាប់ដោយប្រយោលតាមរយៈអនុប្បទាយី។ ឧទាហរណ៍ លោក ក បានបង្កើតកិច្ចសន្យាប្រាតិភោគដោយអនុប្បទានជាមួយ លោក ខ ដោយព្រមព្រៀងគ្នាថា ផ្ទេរសិទ្ធិលើវត្ថុដើម្បីធានាបំណុល។ ដូចនេះវត្ថុត្រូវស្ថិតនៅក្រោមការកាន់កាប់ដោយចំពោះរបស់លោក ក (អ្នកបង្កើត) ដដែល ចំណែកលោក ខ (ម្ចាស់សិទ្ធិ) ទទួលបានការកាន់កាប់វត្ថុដោយប្រយោល។

តាមរយៈការទទួលការកាន់កាប់ទាំងបួនដែលបានរៀបរាប់ខាងលើនេះ នាំឲ្យម្ចាស់សិទ្ធិប្រាតិភោគដោយអនុប្បទានអាចប្រើសិទ្ធិប្រត្យក្សដែលខ្លួនមាន ធ្វើការតតាំងចំពោះតតិយជនបានករណី

ដែលមានការទាមទារ ឬសកម្មភាពផ្សេងៗកើតឡើងលើទ្រព្យដែលបានដាក់ធានា។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មិនបានដក់ចេញនូវទម្រង់ណាមួយឡើយ ជាពិសេសទម្រង់ដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ការប្តូរលក្ខណៈនៃការកាន់កាប់ ព្រោះអ្នកបង្កើតនៅតែអាចបន្តការកាន់កាប់វត្ថុដោយចំពោះ និងអាចប្រើប្រាស់វត្ថុនោះដោយធម្មតា។ ជាធម្មតាទេទម្រង់មួយនេះ មិនត្រូវបានគេប្រើក្នុងកិច្ចសន្យាប្រាតិភោគដោយមានវត្ថុតែមួយដាក់ធានា ហើយខ្លួនមិនបានកាន់កាប់លើវត្ថុដោយផ្ទាល់ឡើយ។ ប៉ុន្តែការប្តូរលក្ខណៈនៃការកាន់កាប់មានការពេញនិយមនៅក្នុងប្រតិបត្តិការប្រាតិភោគដោយអនុប្បទានលើវត្ថុផ្ញុំគ្នា ដោយសារវត្ថុទាំងនោះជាតម្រូវការចាំបាច់របស់អ្នកបង្កើតហើយមិនអាចប្រគល់ទៅឲ្យម្ចាស់សិទ្ធិកាន់កាប់ដោយផ្ទាល់ឡើយ។

## ២.២ ប្រាតិភោគដោយអនុប្បទាននៅក្រុមហ៊ុនវីប្រ៊ោប្រចឹធី

### ២.២.១ ការព្រមព្រៀងលើសេវា

អតិថិជនទាំងអស់ក៏ត្រូវបានទាមទារឲ្យឆ្លងកាត់នូវការសម្ភាសន៍ ជាមួយនឹងតំណាងក្រុមហ៊ុនដូចក្នុងប្រតិបត្តិការបញ្ចាំដែរ ដែលត្រូវពិភាក្សាទៅលើចំណុចមួយចំនួនដូចខាងក្រោមៈ

#### ២.២.១.១ ប្រភេទទ្រព្យ

ចំពោះ ប្រាតិភោគដោយអនុប្បទានរបស់ ក្រុមហ៊ុនវីប្រ៊ោប្រចឹធី គឺអនុវត្តទៅលើ ចលនទ្រព្យមានដូចជា ឡាន និងម៉ូតូប៉ុណ្ណោះ។ ជាគោលការណ៍ចលនទ្រព្យទាំងនោះត្រូវមានភ្ជាប់ជាមួយនូវលិខិតបញ្ជាក់កម្មសិទ្ធិផងដែរ ដែលមានដូចជាកិច្ចសន្យា ទិញ លក់ និងប័ណ្ណសម្គាល់យានយន្តនៃចលនវត្ថុដែលធានាលើបំណុលនោះ ជាដើម។

#### ២.២.១.២ រយៈពេលនៃប្រាតិភោគដោយអនុប្បទាន

ជាក់ស្តែងក្រសួងសេដ្ឋកិច្ចបានកំណត់ឲ្យក្រុមហ៊ុន និងកូនបំណុលត្រូវតែបំពេញលើកិច្ចសន្យាបញ្ចាំរបស់ក្រសួងទុកជារបាយការណ៍ ដោយយោងតាមកិច្ចសន្យាបញ្ចាំនេះ បានកំណត់រយៈពេលនៃការដាក់ធ្វើប្រាតិភោគដោយអនុប្បទានគឺមានតែរយៈ ៤ខែប៉ុណ្ណោះ ដូច្នេះប្រតិបត្តិការបញ្ចាំនៅក្នុងក្រុមហ៊ុនគឺត្រូវតែស្របទៅនឹងការកំណត់នេះ ពោលគឺ រយៈពេលតែ ៤ខែប៉ុណ្ណោះ។ បើចង់បន្តសុពលភាពលុះត្រាតែបង្កើតនូវកិច្ចសន្យាថ្មីម្តងទៀត។

### ២.២.១.៣ សោហ៊ុយលើសេវា

ក្រុមហ៊ុនបានកំណត់ត្រូវដកទឹកពីអតិថិជនក្នុងតម្លៃអតិបរមា ៣ ភាគរយពីអតិថិជនសម្រាប់សោហ៊ុយលើការរៀបចំសំនុំឯកសារផ្សេងៗ សេវាមេធាវី និងសម្រាប់សេវាពិនិត្យគុណភាពយានយន្តជាដើម។

### ២.២.១.៤. អត្រាការប្រាក់

បន្ទាប់ពីអតិថិជនបានព្រមព្រៀងលើសេវាហើយកូនបំណុល ត្រូវមានកាតព្វកិច្ចបង់ការប្រាក់ទៅតាមអត្រាការប្រាក់របស់ក្រុមហ៊ុនជាប្រចាំខែរហូតដល់រួចបំណុល តាមការព្រមព្រៀងដូចមានចែងក្នុងកិច្ចសន្យា។ ជាការពិតណាស់ផលចំណេញរបស់ក្រុមហ៊ុនគឺមួយភាគបានមកពីការប្រាក់នេះហើយ ជាក់ស្តែងក្រុមហ៊ុនវីប្រេ្កាប្រចឹធីបានកំណត់អត្រាការប្រាក់អតិបរិមា ១.៧ ភាគរយនៃចំនួនប្រាក់កម្ចីសរុប។ ជាគោលការណ៍ក្រុមហ៊ុន ចំពោះការប្រាក់ខែដំបូងត្រូវដកនៅដើមចំនួន១ខែជាមុន ក្នុងករណីនេះបើទោះបីជាកូនបំណុលចង់រំលស់បំណុលក្នុងខែដំបូងមុនកំណត់គឺពុំអាចដកការប្រាក់ខែដំបូងនោះបានឡើង។ ដោយឡែកចំពោះខែបន្ទាប់កូនបំណុលត្រូវបង់ការប្រាក់នៅចុងខែតាមកាលបរិច្ឆេទជាក់ហិតដូចនៅក្នុងប្រតិបត្តិការបញ្ចាំផងដែរ។ ករណីដែលអតិថិជនបានបង់ការប្រាក់យឺតជាងថ្ងៃកំណត់រយៈពេល ៣ថ្ងៃ នោះអតិថិជននឹងត្រូវពិន័យបន្ថែមលើការប្រាក់ គឺចំនួន៥ភាគរយនៃការចំនួនការប្រាក់សរុប លើកលែងតែមានករណីពិសេសដូចជា ថ្ងៃឈប់សម្រាកបុណ្យជាតិណាមួយ ឬការអាក់ខានណាមួយរបស់ក្រុមហ៊ុនប៉ុណ្ណោះ។

### ២.២.១.៥ ឯកសារដែលត្រូវភ្ជាប់

ដើម្បីដាក់បញ្ចាំនៅក្រុមហ៊ុនវីប្រេ្កាប្រចឹធី អតិថិជនត្រូវភ្ជាប់មកជាមួយនូវឯកសារមួយចំនួនដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណរបស់បុគ្គលដែលពាក់ព័ន្ធច្បាប់ដើម។
- សៀវភៅគ្រួសារច្បាប់ដើម។
- ប័ណ្ណសម្គាល់យានយន្តដែលត្រូវដាក់ធានាដើម។
- លិខិតទិញ លក់យានយន្តដែលត្រូវដាក់ធានាច្បាប់ដើម។

### ២.២.២ ការបំពេញបែបបទចុះកិច្ចសន្យា

បន្ទាប់ពីអតិថិជនបានព្រមព្រៀងលើលក្ខន្តិកៈ ព្រមទាំងមានភ្ជាប់សំណុំឯកសារគ្រប់គ្រាន់តាមការកំណត់របស់ក្រុមហ៊ុនហើយ នោះអតិជនត្រូវបំពេញនូវកិច្ចសន្យាមួយចំនួនជាមួយនឹងក្រុមហ៊ុន ដូចខាងក្រោមៈ

#### ២.២.២.១ កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

ដើម្បីទទួលបានប្រាក់កម្ចីកូនបំណុលត្រូវធ្វើកិច្ចសន្យាមួយ ជាមួយក្រុមហ៊ុននេះវីហ្រ្គោប្រចឹធី គឺកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់។ ក្នុងកិច្ចសន្យានេះត្រូវបានកំណត់អំពីចំនួនប្រាក់កម្ចី[៣១] ដែលបានព្រមព្រៀងគ្នាហើយ និងមានកំណត់អាត្រាការដែលកូនបំណុលត្រូវមានកាតព្វកិច្ចត្រូវបង់ប្រចាំខែបន្ទាប់ពីកិច្ចសន្យានេះមានអានុភាព។ ដោយឡែកក្រុមហ៊ុនវីហ្គោប្រចឹធីកំណត់ឲ្យកូនបំណុលអាចពន្យាពេលនៃការបង់ការប្រាក់តែរយៈពេល ៣ថ្ងៃប៉ុណ្ណោះបន្ទាប់ពីថ្ងៃកំណត់ត្រូវបង់ការប្រាក់ តែបើពុំដូចនោះទេ កូនបំណុលត្រូវបង់ប្រាក់ពិន័យចំនួន ៥ ភាគរយនៃតម្លៃការប្រាក់។

#### ២.២.២.២ លិខិតធានាអះអាងចំពោះចលនវត្ថុសម្រាប់ជាប្រាតិភោគដោយអនុប្បទាន

លិខិតធានាអះអាងចំពោះចលនវត្ថុសម្រាប់ជាប្រាតិភោគដោយអនុប្បទាន គ្រាន់តែជាលិខិតមួយដែលកូនបំណុលត្រូវបំពេញដើម្បីធានាអះអាងថាចលនវត្ថុ ដែលត្រូវដាក់ធានានោះគឺពិតជាកម្មសិទ្ធិផ្ទាល់របស់ខ្លួនពិតប្រាកដមែន និងមិនជាប់ក្នុងបទល្មើសព្រហ្មទណ្ឌណាមួយឡើយ ឬពាក់ព័ន្ធនឹងការហាមឃាត់ ការរឹបអូសលក់ដោយតុលាការឡើយ ជាដើម។ ផ្ទុយទៅវិញបើសិនវាបង្កឲ្យមានការខូចខាតណាមួយចំពោះក្រុមហ៊ុនកូនបំណុលត្រូវទទួលខុសត្រូវទាំងស្រុង លើសំណងការខូចខាតនោះ ។ លិខិតនេះធ្វើឡើងដើម្បីធានាថាចលនវត្ថុនោះមានលក្ខណៈគ្រប់គ្រាន់ សម្រាប់ប្រតិបត្តិការប្រាតិភោគអនុប្បទាន។

#### ២.២.២.៣ កិច្ចព្រមព្រៀងបន្ថែមលើកិច្ចសន្យាទទួលប្រាតិភោគដោយអនុប្បទាន

នៅក្នុងកិច្ចព្រមព្រៀងបន្ថែមលើកិច្ចសន្យាទទួលប្រាតិភោគ ដោយអនុប្បទានបានកំណត់អំពីការព្រមព្រៀងរបស់កូនបំណុលក្នុងការដាក់ចលនវត្ថុរបស់ខ្លួននោះ សម្រាប់ប្រាតិភោគដោយអនុ-ប្បទាន និងឯកភាពផ្ទេរសិទ្ធិកាន់កាប់ដោយចំពោះមកឲ្យក្រុមហ៊ុននូវទ្រព្យប្រាតិភោគ។ ហើយតាមរយៈកិច្ចព្រមព្រៀងនេះកូនបំណុលបើសិនមិនគោរព ឬខកខានមិនបំពេញកាតព្វកិច្ចរបស់ខ្លួន នោះ

---

៣១ ប្រការ ២នៃកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់

ក្រុមហ៊ុនមានសិទ្ធិចាត់ចែងប្តូរជាប្រាក់ ឬធ្វើអនុប្បទានស្ថាពរនូវទ្រព្យប្រាតិភោគនោះបានដើម្បីទូទាត់បំណុល។

### ២.២.២.៤ កិច្ចសន្យាទទួលប្រាតិភោគដោយអនុប្បទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តាមរយៈការតម្រូវរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនោះក្រុមហ៊ុនក៏ត្រូវធ្វើកិច្ចសន្យាទទួលប្រាតិភោគដោយអនុប្បទានដែលបានកំណត់ដោយក្រសួងនេះចំនួន ២ច្បាប់ហើយត្រូវក្រុមហ៊ុនជាអ្នកទុក ១ ច្បាប់ និងកូនបំណុលទុក១ច្បាប់។

### ២.២.៣ ការដោះបំណុល

នៅពេលដែលកូនបំណុលបានទូទាត់សងបំណុលគ្រប់ចំនួនហើយ ភ្នាក់ងារក្រុមហ៊ុននឹងចេញជាលិខិតដោះបំណុលដូចនៅក្នុងផ្នែកនៃប្រតិបត្តិការបញ្ចាំដែរ ដោយមានបញ្ជាក់ថាកូនបំណុលបានសងបំណុលគ្រប់ចំនួនហើយ ហើយបន្ទាប់ពីចេញលិខិតនេះហើយ រាល់ការខូចខាតបាត់បង់ផ្សេងៗរបស់កូនបំណុលពុំពាក់ព័ន្ធនឹងក្រុមហ៊ុនដោយធ្វើឡើងចំនួន ២ច្បាប់(១ ច្បាប់ក្រុមហ៊ុនជាអ្នកកាន់ និង ១ច្បាប់ទៀតកូនបំណុលជាអ្នកកាន់) ដោយពុំចាំបាច់មានជាទម្រង់យថាភូតដូចក្នុងប្រតិបត្តិការបញ្ចាំឡើយ ហើយក្រុមហ៊ុនត្រូវប្រគល់សំណុំឯកសារដែលកូនបំណុលបានដាក់តម្កល់ទៅឲ្យកូនបំណុលវិញមានដូចជាប័ណ្ណសម្គាល់យានយន្ត លិខិតទិញ លក់ពីកម្មសិទ្ធិករដើមមកកូនបំណុល អត្តសញ្ញាណប័ណ្ណជាដើម។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការបកស្រាយអំពីប្រតិបត្តិការប្រាតិភោគ នៅក្រុមហ៊ុនវីប្រ៉ោប្រចឹធីរួចមកហើយ ដែលបង្ហាញពីការអនុវត្តប្រតិបត្តការប្រាតិភោគនៅក្រុមហ៊ុននេះ ដោយឡែកវាបានបន្សល់ទុកនូវផលល្អមួយចំនួននៅក្នុងប្រតិបត្តិការនេះ។

ក្នុងប្រតិបត្តិការបញ្ចាំនេះក្រុមហ៊ុនវីប្រ៉ោប្រចឹធីបានអនុញ្ញាតឲ្យកូនបំណុល អាចមានសិទ្ធិប្រើប្រាស់បើមានការរយៈការស្នើសុំ ការណ៍នេះវាបង្កឲ្យមានភាពងាយស្រួលមួយសម្រាប់កូនបំណុលពិសេសចំពោះករណីទ្រព្យបញ្ចាំដែលជាផ្ទះសម្បែងតែម្ដង ដែលកូនបំណុលអាចស្នាក់នៅផ្ទះរបស់ខ្លួនបានដោយមិនចាំបាច់ធ្វើការផ្លាស់ទីលំនៅដ្ឋានឡើយ ដោយហេតុតែវាមានភាពងាយស្រួលនោះហើយ ក៏អាចជាមធ្យោបាយមួយសម្រាប់ដែលអាចធ្វើឲ្យក្រុមហ៊ុនទទួលបានអតិថិជនច្រើនផងដែរ។

ម្យ៉ាងវិញទៀតចំពោះប្រតិបត្តិការប្រាតិភោគដោយអនុប្បទាននៅក្នុងក្រុមហ៊ុនេះវីប្រ៉ោប្រចឹធីវាគឺជាជម្រើសមួយល្អផងដែរសម្រាប់ការដាក់នូវចលនវត្ថុក្នុងការធានា ប្រសើរជាជាងការដាក់ចលនវត្ថុក្នុងការធានាជាទម្រង់ការបញ្ចាំចលនវត្ថុ ដោយហេតុតែវាមានភាពងាយស្រួលក្នុងការទូទាត់សងបំណុល ដោយពុំចាំបាច់ឆ្លងកាត់នីតិវិធីតុលាការ ក្នុងករណីដែលកូនបំណុលពុំអាចបំពេញកាតព្វកិច្ចសងបំណុល។ វាអាចជាវិធីសាស្ត្រមួយដែលចំនេញពេលវេលា និងថវិកាផងដែរចំពោះក្រុមហ៊ុន។

ផ្ទុយទៅវិញ យើងក៏សង្កេតឃើញផលអាក្រក់ចំពោះចំណុចមួយចំនួនផងដែរ។

ចំពោះការដកសោហ៊ុយលើសេវា ចំពោះប្រតិបត្តិការបញ្ចាំរបស់ក្រុមហ៊ុនជាក់ស្ដែងអតិបរមា ១០ភាគរយនៃចំនួនប្រាក់កម្ចី វាហាក់ដូចជាការកំណត់មួយដែលមានកម្រិតខ្ពស់នៅឡើយ។ហើយអាត្រាការប្រាក់របស់ក្រុមហ៊ុននេះក្នុងមួយខែអតិបរិមា ១.៧ ភាគរយនៃប្រាក់កម្ចី នោះការប្រាក់ក្នុងមួយឆ្នាំស្មើនឹង ២០.៤ ភាគរយ នេះសរឲ្យឃើញថាអាត្រាការប្រាក់នេះលើសអំពីអាត្រាការប្រាក់ដែលត្រូវបានកម្រិតនៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ១២៨កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ដែលបានកំណត់អាត្រាដែលត្រូវបានកម្រិតត្រឹមតែ ១៨ភាគរយក្នុងមួយឆ្នាំប៉ុណ្ណោះដែលអាត្រាការប្រាក់ដែលបានកម្រិតនេះសម្ដៅទៅលើអាត្រាការប្រាក់អតិបរមា នៃអាត្រាការប្រាក់ដែលព្រមព្រៀងរបស់គូភាគី បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ៥៨៥ កថាខណ្ឌទី១។

ហេតុដូច្នេះជាសំណើ សម្រាប់ដំណោះស្រាយលើបញ្ហាខាងលើ ក្រុមហ៊ុនគួរតែបន្ទាបនូវសោហ៊ុយលើសេវាប្រាតិភោគ ក៏ដូចជាអាត្រាការប្រាក់ឲ្យបានត្រឹមត្រូវតាមការកំណត់នៃច្បាប់ ដែលជាហេតុមួយដែលអាចធានាបាននូវនិរន្តរភាពនៃអាជីវកម្មរបស់ខ្លួន ហើយក៏ជាផ្នែកមួយនៃការចូលរួមលុបបំបាត់នៅភាពក្រីក្ររបស់ប្រជាពលរដ្ឋ ដែលជំរុញឲ្យមានការអភិវឌ្ឍប្រទេសជាតិផងដែរ។

# ឯកសារពិគ្រោះ


១. ក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧

២. សេចក្តីកំណត់ចំពោះមាត្រានីមួយៗក្រមរដ្ឋប្បវេណី ភាគទី៥ បោះពុម្ពនៅក្នុងខែមីនា ឆ្នាំ ២០១២

៣. សន្ទានុក្រមរដ្ឋប្បវេណី

៤. ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១១

៤. ច្បាប់ភូមិបាលឆ្នាំ ២០០១

៥. ក្រឹត្យច្បាប់លេខ ៣៨ ក្រច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៨៨

៦. ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២៨ សហវ.ប្រក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ ស្តីពីការ ផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវ-កម្មទទួលប្រាតិភោគដោយអនុប្បទាន

៧. ប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ១២៨កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ស្តីពីអាត្រាការប្រាក់ដែលត្រូវបានកម្រិត

៨. សៀវភៅសិក្សាស្តីពី "នីតិកិច្ចសន្យា" ឆ្នាំ២០១៣ រៀបរៀងដោយលោក **ខិន វណ្ណារ៉ា** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

៩. សៀវភៅសិក្សាស្តីពី "នីតិប្រាតិភោគ" ឆ្នាំ ២០១៣ រៀបរៀងដោយលោក **ចាំង ស៊ីណាត** សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

១០. វចនានុក្រមខ្មែររបស់ សម្តេចសង្ឃ ជួន ណាត បោះពុម្ពឆ្នាំ ១៩៦៧

# បញ្ជីរាយនាមឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ០១

- ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ ០២៨ សហវ.ប្រក ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១០ ស្តីពីការ ផ្តល់អាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ និងទិញ លក់ទ្រព្យបញ្ចាំ និងអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន
- ប្រកាសរបស់ក្រសួងយុត្តិធម៌លេខ ១២៨កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ស្តីពី អាត្រាការប្រាក់ដែលត្រូវបានកម្រិត

## ឧបសម្ព័ន្ធទី ០២

- កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ចំពោះការបញ្ចាំ
- កិច្ចសន្យាបញ្ចាំអចលនវត្ថុ

## ឧបសម្ព័ន្ធទី ០៣

- ពាក្យសុំចុះបញ្ជីអំពីការបង្កើតសិទ្ធិលើការបញ្ចាំ
- កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ

## ឧបសម្ព័ន្ធទី ០៤

- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ
- លិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង

## ឧបសម្ព័ន្ធទី ០៥

- កិច្ចសន្យាបញ្ចាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- កិច្ចសន្យាទទួលប្រាតិភោគដោយអនុប្បទានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបសម្ព័ន្ធទី ០៦

- កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ចំពោះប្រាតិភោគដោយអនុប្បទាន

- លិខិតបញ្ជាក់ និងធានាអះអាងចំពោះចលនវត្ថុសម្រាប់ជាប្រាតិភោគដោយអនុប្បទាន
- កិច្ចព្រមព្រៀងបន្ថែមលើកិច្ចសន្យាទទួលប្រាតិភោគដោយអនុប្បទាន
- កិច្ចព្រមព្រៀងប្រគល់សិទ្ធិប្រើប្រាស់

## ឧបសម្ព័ន្ធទី ០៧

- លិខិតបញ្ជាក់ការរួចបំណុល

## ឧបសម្ព័ន្ធទី ០៨

- ទម្រង់លិខិតសម្ភាសន៍អតិថិជន
- តារាងប្រគល់ និងទទួលការប្រាក់